SUMITOMO
ELECTRIC

# CODE OF CONDUCT
# ក្រមប្រតិបត្តិ



SUMITOMO
ELECTRIC
GROUP



## ស្មារតីក្រុមហ៊ុន Sumitomo

Banji-nissei

萬事入精

Shinyo-kakujitsu

信用確実

Fusu-furi

不趨浮利

មេសា 2018

**ជូនចំពោះមិត្តរួមការងារទាំងអស់ជាទីមេត្រី!**

ជាមួយនឹងមោទនភាពនៃការពង្រីកប្រវត្តិសាស្ត្ររបស់ខ្លួនអស់រយៈពេលជាង 120 ឆ្នាំមកនេះ ក្រុមហ៊ុន Sumitomo Electric Group (“SEG”) មានប្រពៃណីយូរអង្វែងក្នុងការប្រកបអាជីវកម្មស្របទៅតាមគោការណ៍ស្មារតីក្រុមហ៊ុន Sumitomo។ ជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីភាពល្អប្រសើរនៅក្នុងការងាររបស់យើង ហើយយើងខិតខំប្រឹងប្រែងដើម្បីសុចរិតភាពនៅក្នុងការប្រកបអាជីវកម្មរបស់យើង។ យើងប្រតិបត្តិមិនមែនតែនៅតាមខ្លឹមសារនិងស្មារតីច្បាប់និងបទប្បញ្ញត្តិនោះទេ ប៉ុន្តែក៏ស្របទៅតាមស្តង់ដាក្រមសីលធម៌ខ្ពស់បំផុតផងដែរ។

គោលការណ៍នៃស្មារតីក្រុមហ៊ុន Sumitomo ដែលបានបង្កើតឡើង 400 ឆ្នាំមកនេះ ផ្តល់ជាមគ្គុទេសក៏ដល់សកម្មភាពអាជីវកម្មរបស់យើងជារៀងរាល់ថ្ងៃ។ យើងទាំងអស់គ្នាចាំបាច់ត្រូវបង្ហាញពីស្មារតីក្រុមហ៊ុន Sumitomo នៅក្នុងការងាររបស់យើង។

- **Banji-nissei** – ធ្វើការដោយសេចក្តីស្មោះត្រង់អស់ពីចិត្ត មិនមែនតែនៅក្នុងអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកផងដែរ។
- **Shinyo-kakujitsu** – ផ្តល់ភាពសំខាន់ទៅលើសុចរិតភាព និងការគ្រប់គ្រងល្អ។
- **Fusu-furi** – មិនត្រូវលះបង់សុចរិតភាពដើម្បីផលប្រយោជន៍ងាយៗនោះទេ។

ក្រមប្រតិបត្តិនេះ ដែលត្រូវបានអនុម័តទទួលយកដោយក្រុមប្រឹក្សាភិបាលរបស់យើង បង្កើតឡើងលើមូលដ្ឋាននៃស្មារតីក្រុមហ៊ុន Sumitomo និងមានចែងអំពីស្តង់ដាប្រតិបត្តិដែលជាក្តីរំពឹងរបស់យើងម្នាក់ៗ និងជួយផ្តល់ជាមគ្គុទេសក៏ក្នុងការប្រកបអាជីវកម្មដោយសុចរិតភាព។ បើទោះបីជាវាមិនអាចគ្របដណ្តប់លើស្ថានភាពគ្រប់បែបយ៉ាងបានក៏ពិតមែន ប៉ុន្តែវាផ្តល់ដល់អ្នកនូវធនធានដែលអ្នកត្រូវការចាំបាច់ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយក្រមសីលធម៌។

យើងម្នាក់ៗ ក្នុងនាមជាសមាជិករបស់ក្រុមហ៊ុន SEG បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធានាដល់ក្រុមរបស់យើងទាំងមូលឲ្យអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាការទទួលខុសត្រូវរបស់យើងម្នាក់ៗ ត្រូវតែដឹង យល់ និងអនុវត្តតាមក្រមនេះ និងរាល់គោលនយោបាយយោងទាំងអស់នៅក្នុងក្រមនេះ។

ខ្ញុំសូមស្នើសុំឲ្យយើងម្នាក់ៗ ធ្វើការប្តេជ្ញាចិត្តផ្ទាល់ខ្លួនដើម្បីប្រកបអាជីវកម្មស្របទៅតាមស្មារតីក្រុមហ៊ុន Sumitomo និងក្រមប្រតិបត្តិនេះ។ សូមពិនិត្យចំពោះក្រមនេះនៅក្នុងពេលបំពេញការងាររបស់អ្នក ប្រើប្រាស់ការវិនិច្ឆ័យដែលត្រឹមត្រូវ និងស្វែងរកការណែនាំប្រសិនបើអ្នកត្រូវការជំនួយបន្ថែម។ ក្រុមហ៊ុន SEG ផ្តល់ជូនដល់អ្នកនូវទីកន្លែងជាច្រើនដែលអ្នកត្រូវទៅរកជំនួយបាននៅពេលអ្នកមានសំណួរ ឬចង់លើកឡើងពីក្តីកង្វល់នានា រួមទាំងអ្នកគ្រប់គ្រងរបស់អ្នក ផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក និងផ្នែកនីតិកម្ម ក៏ដូចជាការិយាល័យប្រតិបត្តិតាមនិងគ្រប់គ្រងហានិភ័យក្នុងប្រទេសជប៉ុន។

ដោយសារយើងបន្តផ្តោតជាសំខាន់លើការពង្រីកអាជីវកម្មរបស់យើង យើងក៏ត្រូវចងចាំថាត្រូវធ្វើអាជីវកម្មប្រកបដោយសុចរិតភាពផងដែរ។ សូមអរគុណដល់ការងារដែលអ្នកទាំងអស់គ្នាធ្វើសម្រាប់ក្រុមហ៊ុន SEG ជារៀងរាល់ថ្ងៃ និងដល់ការប្តេជ្ញាចិត្តក្នុងការបំពេញការងារស្របតាមស្មារតីក្រុមហ៊ុន Sumitomo។

**Osamu Inoue**
ប្រធាន & នាយកអចិន្ត្រៃយ៍ផ្នែកប្រតិបត្តិការ
ក្រុមហ៊ុន Sumitomo Electric Industries, Ltd.

# តារាងមាតិកា

**ការប្តេជ្ញាចិត្តរបស់យើងចំពោះក្រម**


ក្រមរបស់យើង ........ 5

តើក្រមនេះអនុវត្តចំពោះអ្នកណាខ្លះ? ........ 5

តើមានអ្វីកើតឡើង ប្រសិនបើច្បាប់ក្នុងស្រុករបស់យើង មានភាពខុសគ្នាពីគោលនយោបាយនៅក្នុងក្រមនេះ? ........ 5

កម្មវិធីប្រតិបត្តិតាម និងក្រមសីលធម៌របស់យើង ........ 5

ទំនួលខុសត្រូវរបស់យើង ........ 5

ទំនួលខុសត្រូវរបស់ប្រធាន និងអ្នកដឹកនាំ ........ 6

ស្វែងរកការណែនាំ និងរាយការណ៍ពីក្តីកង្វល់នានា ........ 6

ស្វែងរកការណែនាំ ........ 6

រាយការណ៍ពីក្តីកង្វល់នានា ........ 6

ប្រព័ន្ធទូរសព្ទពេលមានអាសន្ន ........ 7

មិនត្រូវមានការសងសឹកឡើយ ........ 7

ក្រោយពីទទួលបានរបាយការណ៍ ........ 7

ការពិន័យចំពោះបទរំលោភបំពាន។ ........ 7


**ការប្តេជ្ញាចិត្តរបស់យើងចំពោះ ក្រមសីលធម៌ផ្នែកធុរកិច្ច**


ការអនុវត្តទៅតាមច្បាប់ ........ 8

ការប្រាស្រ័យទាក់ទងដោយយុត្តិធម៌ និងស្មោះត្រង់ ........ 8

យើងគោរពតាមច្បាប់ស្តីពីការប្រឆាំងការជឿទុកចិត្ត និងការប្រកួតប្រជែង ........ 8

យើងមិនផ្តល់ជូន ឬទទួលសំណូកឡើយ ........ 9

អំណោយ និងការកែកម្សាន្ត ........ 10

ការដោះស្រាយបញ្ហាជាមួយរដ្ឋាភិបាល ........ 11

ជំនួញអន្តរជាតិ ........ 11

ការធ្វើជំនួញនៅក្នុងស្រុក ........ 12

វិភាគទាននិងសកម្មភាពនយោបាយ ........ 13


**ការប្តេជ្ញាចិត្តរបស់យើងចំពោះ ក្រុមហ៊ុន**


គណនេយ្យនិងកំណត់ត្រាទាំងឡាយរបស់ក្រុមហ៊ុន ........ 13

ជម្លោះផលប្រយោជន៍ ........ 13

ការការពារ និងការប្រើប្រាស់ដ៏ត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងការការពារការបោកបន្លំ ........ 14

ព័ត៌មានសម្ងាត់ និងកម្មសិទ្ធិបញ្ញាផ្សេងៗ ........ 15

ប្រព័ន្ធអ៊ីនធើណិត និងការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន ........ 15

ការទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយនិងផ្នែកផ្សេងៗ ........ 16

**ការប្តេជ្ញាចិត្តរបស់យើងចំពោះបុគ្គលិករបស់យើង និងបរិស្ថានរបស់យើង**
ធ្វើការគោរពគ្នាទៅវិញទៅមក.....17
ប្រឆាំងចំពោះការរើសអើង និងការរុកគួនរំខានឆាឆៅ.....17
សិទ្ធិឯកជនភាព និងទិន្និន័យបុគ្គល.....17
សុវត្ថិភាពកន្លែងធ្វើការ.....18
គុណភាព.....18
ការអនុវត្តតាមផ្នែកបរិស្ថាន.....18
សិទ្ធិមនុស្ស.....18

**តើខ្ញុំត្រូវទៅរកនរណាឲ្យជួយ?**.....19



ការប្តេជ្ញាចិត្តរបស់យើងចំពោះ

# ក្រម



## ក្រមរបស់យើង

ក្រមនេះ គឺជាសេចក្តីថ្លែងមួយនៃគុណតម្លៃរបស់យើង និងស្តង់ដាប្រតិបត្តិដែលម្នាក់ៗត្រូវអនុវត្ត។ ក្រមនេះ រៀបរាប់ពីគោលការណ៍គ្រឹះ និងគោលនយោបាយគន្លឹះ ដែលគ្របដណ្តប់លើរបៀបដែលយើងប្រកបអាជីវកម្ម។ ដោយសារអាជីវកម្មរបស់យើង ពឹងផ្អែកលើកេរ្តិ៍ឈ្មោះរបស់យើង ក្នុងឧទាហរណ៍ជាច្រើន គោលការណ៍ដែលយោងនៅក្នុងក្រមនេះ គឺស្ថិតលើសពីលក្ខខណ្ឌតម្រូវរបស់ច្បាប់។

អ្នកអាចអានក្រមនេះបានដោយយកចិត្តទុកដាក់ និងត្រូវប្រាកដថាអ្នកយល់ដឹងពីក្រម និងសារៈសំខាន់នៃក្រមនេះដើម្បីជោគជ័យរបស់ក្រុមហ៊ុនយើង។ ប្រសិនបើអ្នកមានសំណួរអ្វី សូមពិភាក្សាជាមួយអ្នកគ្រប់គ្រងរបស់អ្នក ឬប្រភពធនធានផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ។

**តើក្រមនេះអនុវត្តចំពោះអ្នកណាខ្លះ?**

ក្រមនេះអនុវត្តចំពោះនិយោជិត មន្ត្រី និងប្រធានក្រុមហ៊ុន នៅគ្រប់កម្រិតទាំងអស់ រួមទាំងនិយោជិតទាំងអស់របស់ក្រុមហ៊ុនបុត្តសម្ព័ន្ធ និងក្រុមហ៊ុនប្រតិបត្តិការផ្សេងទៀតដែលមានការគ្រប់គ្រង។ យើងក៏រំពឹងថាដៃគូអាជីវកម្មរបស់យើងបំពេញការងារក្នុងរបៀបដែលមានសង្គតិភាពជាមួយគោលការណ៍នៃក្រមរបស់យើង នៅពេលដែលពួកគេប្រកបអាជីវកម្មជាមួយយើង។

**តើមានអ្វីកើតឡើង ប្រសិនបើច្បាប់ក្នុងស្រុករបស់យើង មានភាពខុសគ្នាពីគោលនយោបាយនៅក្នុងក្រមនេះ?**

ក្នុងនាមជាក្រុមហ៊ុនលំដាប់ពិភពលោកមួយ អាចមានពេលជាច្រើនដែលច្បាប់ក្នុងស្រុក ឬលក្ខខណ្ឌតម្រូវផ្នែកច្បាប់ផ្សេងទៀត អាចខុសគ្នាពីស្តង់ដាដែលមានចែងនៅក្នុងក្រមនេះ ឬនៅត្រង់ចំណុចដែលមានលក្ខណៈផ្ទុយនឹងលក្ខខណ្ឌតម្រូវផ្នែកច្បាប់។ យើងតែងតែអនុវត្តតាមច្បាប់ជាធរមាន។ ប្រសិនបើអ្នកដឹងពីទំនាស់ដែលអាចនឹងកើតឡើងរវាងក្រមរបស់យើងនឹងច្បាប់ សូមទាក់ទងមកកាន់នាយកដ្ឋាននីតិកម្មដើម្បីទទួលបានជំនួយ។

## កម្មវិធីប្រតិបត្តិតាម និងក្រមសីលធម៌របស់យើង

កម្មវិធីប្រតិបត្តិតាម និងក្រមសីលធម៌របស់យើង គឺជាឧទាហរណ៍មួយផ្សេងទៀតនៃការប្តេជ្ញាចិត្តរបស់យើងក្នុងការប្រកបអាជីវកម្មស្របទៅតាមស្មារតីក្រុមហ៊ុន Sumitomo។

កម្មវិធីនេះមានគោលដៅងាយៗ ប៉ុន្តែសំខាន់ — ដើម្បីជួយឲ្យយើងម្នាក់ៗយល់ដឹងអំពីអ្វីដែលច្បាប់តម្រូវ និងដើម្បីផ្តល់នូវធនធាននានាដើម្បីជួយយើងឲ្យអនុវត្តតាម។ ការិយាល័យប្រតិបត្តិតាម & គ្រប់គ្រងហានិភ័យ ដែលដឹកនាំដោយគណៈកម្មការប្រតិបត្តិតាមរបស់ក្រុមហ៊ុន SEG មានសិទ្ធិអំណាច និងទំនួលខុសត្រូវដ៏សំខាន់សម្រាប់ការត្រួតពិនិត្យលើកម្មវិធីប្រតិបត្តិតាមនិងក្រមសីលធម៌របស់យើង។ បន្ថែមលើនេះ បណ្តាក្រុមហ៊ុនរបស់យើងនីមួយៗមានផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋាន ដែលជួយដល់កម្មវិធីនេះ និងជាអ្នកដែលធ្វើជាធនធានសម្រាប់យើងម្នាក់ៗ។ ក្រមនេះ គឺជាផ្នែកដ៏មានសារៈសំខាន់នៃកម្មវិធីនេះ និងជាការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនចំពោះក្រមសីលធម៌អាជីវកម្ម។

## ទំនួលខុសត្រូវរបស់យើង

យើងម្នាក់ៗត្រូវប្តេជ្ញាចិត្តដូចខាងក្រោម៖

- អាន និងស្វែងយល់ពីក្រមនេះ និងគោលនយោបាយរបស់ក្រុមហ៊ុនយើងដែលអនុវត្តចំពោះការងាររបស់យើង។
- អនុវត្តតាមខ្លឹមសារ និងស្មារតីច្បាប់ ក្រមនេះ និងគោលនយោបាយទាំងឡាយរបស់ក្រុមហ៊ុន។
- រាយការណ៍ពីការរំលោភបំពានដែលអ្នកបានដឹង ឬមានការសង្ស័យចំពោះក្រមច្បាប់ជាធរមាន ឬគោលនយោបាយក្រុមហ៊ុនទៅកាន់ប្រធានរបស់អ្នក ឬធនធានផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រម។
- ស្វែងរកការណែនាំពីប្រធានរបស់អ្នក ផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក ផ្នែកនីតិកម្ម ផ្នែកគ្រប់គ្រងធនធានមនុស្ស ឬធនធានណាមួយនៃធនធានដទៃផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រម ក្នុងករណីអ្នកត្រូវការជំនួយ។
- ចូលរួមសហការនៅក្នុងស៊ើបអង្កេត សវនកម្ម និងការត្រួតពិនិត្យផ្សេងទៀតនៅក្នុងក្រុមហ៊ុន។

## ទំនួលខុសត្រូវរបស់ប្រធាន និងអ្នកដឹកនាំ

ប្រសិនបើអ្នកជាប្រធាន ឬអ្នកដឹកនាំ អ្នកមានកាតព្វកិច្ចពិសេសមួយក្នុងការបង្ហាញពីគុណតម្លៃនានាដែលឆ្លុះបញ្ចាំងពីក្រមរបស់យើង និងស្មារតីក្រុមហ៊ុន Sumitomo និងដើម្បីជួយដល់និយោជិតរបស់យើងក្នុងការអនុវត្តឲ្យបានដូចៗគ្នា។ ប្រធាននិង អ្នកដឹកនាំរបស់ក្រុមហ៊ុនយើង ត្រូវធ្វើការប្ដេជ្ញាចិត្តចំពោះចំណុចដូចខាងក្រោម៖

- **បង្កើតវប្បធម៌ "និយាយការពិត"។** រក្សាបរិយាកាសការងារដែលនិយោជិតមានភាពងាយស្រួលក្នុងការសាកសួរសំណួរ និងលើកឡើងពីក្ដីកង្វល់នានា។

- **ធ្វើជាជនគំរូម្នាក់។** ធ្វើជាគំរូក្នុងការប្រកបអាជីវកម្មស្របទៅតាមក្រមនេះ និងស្មារតីក្រុមហ៊ុន Sumitomo។

- **គាំទ្រដល់កម្មវិធីប្រតិបត្តិតាម និងក្រមសីលធម៌។** លើកទឹកចិត្តនិយោជិតឲ្យអានក្រមនេះ។ ត្រូវធានាថាមនុស្សដែលអ្នកបំពេញការងារជាមួយ មានការយល់ដឹងអំពីគោលនយោបាយនានាដែលអនុវត្តចំពោះការងាររបស់ពួកគេ។ គាំទ្រដល់ការបណ្ដុះបណ្ដាល និងការប្រាស្រ័យទាក់ទងផ្នែកប្រតិបត្តិតាមរបស់ក្រុមហ៊ុន។ និងជួយដល់ការអនុវត្តកម្មវិធីប្រតិបត្តិតាម និងក្រមសីលធម៌នៅក្នុងផ្នែករបស់អ្នក។

- **ស្ដាប់និងផ្ដល់ការណែនាំ។** ត្រូវមានពេលជួបជាមួយនិយោជិតដែលមករកអ្នកដើម្បីលើកឡើងពីក្ដីកង្វល់ និងសាកសួរសំណួរ។ ជួយនិយោជិតក្នុងការធ្វើសេចក្ដីសម្រេចប្រកបដោយក្រមសីលធម៌។

- **បញ្ជូនក្ដីកង្វល់នេះទៅកាន់ផ្នែកសមស្រប។** ប្រសិនបើអ្នកបានដឹងពីការអនុវត្តការងារដែលសង្ស័យថាមានការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវ សូមបញ្ជូនបញ្ហានេះទៅផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក ផ្នែកនីតិកម្ម ផ្នែកគ្រប់គ្រងធនធានមនុស្ស ឬធនធានដទៃផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ។

## ស្វែងរកការណែនាំ និងរាយការណ៍ពីក្ដីកង្វល់នានា

### ស្វែងរកការណែនាំ

ក្រមនេះមិនអាចផ្ដល់ដំណោះស្រាយដល់គ្រប់ស្ថានភាពដែលអាចនឹងកើតឡើងបានទេ។ ក្នុងករណីអ្នកមិនច្បាស់ថាតើច្បាប់ ឬ គោលនយោបាយអ្វីរបស់ក្រុមហ៊ុនត្រូវអនុវត្តតាមទេនោះ ឬក្នុងករណីអ្នកយល់ថាខ្លួនអ្នកស្ថិតក្នុងស្ថានភាពមួយផ្នែកក្រមសីលធម៌ដ៏លំបាកលំបិននោះ សូមស្វែងរកការណែនាំពីប្រភពមួយនៃប្រភពជាច្រើនដែលអ្នកអាចរកបាន ដោយក្នុងនោះមានប្រធានរបស់អ្នកផ្ទាល់ ផ្នែកទំនាក់ទំនងប្រតិបត្តិតាមនៅក្នុងមូលដ្ឋានរបស់អ្នក ផ្នែកនិតិកម្ម ឬផ្នែកគ្រប់គ្រងធនធានមនុស្ស។

### រាយការណ៍ពីក្ដីកង្វល់នានា

ក្នុងករណីអ្នកដឹងពីករណីសង្ស័យ ឬជាក់ស្ដែងនៃការរំលោភច្បាប់ក្រម ឬគោលនយោបាយរបស់ក្រុមហ៊ុននោះ អ្នកមានកាត្រូវដើម្បីរាយការណ៍ពីករណីនេះ។ ធ្វើការរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវ ឬកង្វល់ទាំងឡាយផ្សេងទៀត ដែលនឹងជួយការពារដល់ក្រុមហ៊ុនរបស់យើង មិត្តរួមការងាររបស់យើង និងសហគមន៍របស់យើង។ ក្រុមហ៊ុនរបស់យើងផ្ដល់ដល់អ្នកនូវមធ្យោបាយជាច្រើន ដែលអ្នកអាចរាយការណ៍ពីក្ដីកង្វល់បាន ដោយក្នុងនោះមាន៖

- ប្រធានរបស់អ្នក
- ផ្នែកប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក
- ផ្នែកនីតិកម្ម
- ផ្នែកគ្រប់គ្រងធនធានមនុស្ស
- ប្រព័ន្ធទូរសព្ទពេលមានអាសន្ន (ផ្ទៃក្នុង/ខាងក្រៅ)

**សំណួរ** ខ្ញុំមិនពេញចិត្តនឹងអ្វីមួយដែលកំពុងតែកើតឡើងនៅកន្លែងធ្វើការរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនមានភស្តុតាងរឹងមាំថាក្រមរបស់យើងកំពុងត្រូវបានគេរំលោភបំពាននោះទេ។ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្ដេច?

**ចម្លើយ** អ្នកគួរតែស្វែងរកការណែនាំ ឬរាយការណ៍ពីក្ដីកង្វល់របស់អ្នកដោយប្រើប្រាស់ធនធានដែលជាធនធានទាំងឡាយដូចដែលបានរៀបរាប់នៅក្នុងក្រម។ ប្រសិនបើអ្នកនៅរង់ចាំវាអាចនឹងយឺតពេល ដើម្បីការពារផលប៉ះពាល់ចំពោះក្រុមហ៊ុន ឬអ្នកដទៃផ្សេងទៀតពីការរំលោភបំពានដែលអាចកើតឡើង។ ក្រុមហ៊ុននឹងស៊ើបអង្កេតចំពោះបញ្ហាយ៉ាងត្រឹមត្រូវ។

### ប្រព័ន្ធទូរសព្ទពេលមានអាសន្ន

ក្រុមហ៊ុនរបស់យើងផ្តល់ដល់និយោជិតទាំងឡាយនូវប្រព័ន្ធទូរសព្ទពេលមានអាសន្ន ដែលគេអាចហៅទូរសព្ទចូល ឬផ្ញើរអ៊ីម៉ែល ដើម្បីរាយការណ៍ពីករណីសង្ស័យថាមានការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវ ឬដើម្បីស្វែងរកការណែនាំពីគោលការណ៍របស់ក្រុមហ៊ុន ឬច្បាប់សមស្រប។

នៅកន្លែងការងារភាគច្រើន និយោជិតអាចទាក់ទងមកកាន់ប្រព័ន្ធទូរសព្ទពេលមានអាសន្នបាន។ ច្បាប់គ្រប់គ្រងទៅលើប្រព័ន្ធទូរសព្ទពេលមានអាសន្ន មានលក្ខណៈខុសៗគ្នានៅក្នុងប្រទេសផ្សេងគ្នាមួយចំនួន និងនៅពេលខ្លះមានលក្ខណៈរឹតត្បិតខ្លាំង។ នៅក្នុងករណីទាំងនេះ អ្នកគួរតែពិគ្រោះជាមួយប្រភពទាំងឡាយដូចដែលបានកំណត់ក្នុងក្រម គោលការណ៍ណែនាំផ្ទៃក្នុងក្រុមហ៊ុនរបស់អ្នក ឬនៅលើប្រព័ន្ធទិន្នន័យផ្ទៃក្នុងក្រុមហ៊ុនអ្នកដោយផ្ទាល់ ដើម្បីទទួលបានព័ត៌មានបន្ថែមថាតើអ្នកអាច ហើយប្រសិនបើដូច្នេះមែន តើត្រូវរាយការណ៍ចេញពីប្រទេស ដែលអ្នកកំពុងស្ថិតនៅយ៉ាងដូចម្តេច?

### មិនត្រូវមានការសងសឹកឡើយ

ក្រុមហ៊ុនរបស់យើងហាមឃាត់មិនឲ្យមានការសងសឹកចំពោះនិយោជិតទាំងឡាយណា ដែលធ្វើសេចក្តីរាយណ៍ដោយសុទ្ធចិត្តពីករណីសង្ស័យថាមានការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវនោះឡើយ។ ប្រសិនបើអ្នកបានដឹងពីការសងសឹក (ចំពោះអ្នក ឬនិយោជិតណាម្នាក់ផ្សេងទៀតនោះ) សូមរាយការណ៍ជាបន្ទាន់ទៅកាន់ផ្នែកនីតិកម្ម ឬធនធានណាមួយផ្សេងទៀតដូចដែលបានកំណត់នៅក្នុងក្រមនេះ។ ក្រុមហ៊ុនរបស់យើងនឹងស៊ើបអង្កេតទៅលើបញ្ហា និងចាត់វិធានការសមស្រប។

### ក្រោយពីទទួលបានរបាយការណ៍

របាយការណ៍នៃករណីសង្ស័យថាមានការប្រព្រឹត្តកិរិយាមិនត្រឹមត្រូវនឹងត្រូវបានស៊ើបអង្កេតយ៉ាងត្រឹមត្រូវ និងត្រូវបានចាត់ទុកជាការសម្ងាត់ក្នុងកម្រិតដែលអាចធ្វើទៅបាន។ អ្នកមិនគួរធ្វើការស៊ើបអង្កេតដោយខ្លួនឯងឡើយ។ ការការស៊ើបអង្កេតច្រើនតែពាក់ព័ន្ធ បញ្ហាផ្នែកច្បាប់ដ៏ស្មុគស្មាញ ហើយការធ្វើសកម្មភាពដោយខ្លួនអ្នកផ្ទាល់ អាចនឹងធ្វើឲ្យការស្រាវជ្រាវមិនបានសព្វជ្រុងជ្រោយ និងផ្តល់ផលអវិជ្ជមានទាំងចំពោះអ្នកនិងក្រុមហ៊ុន។

### ការពិន័យចំពោះបទរំលោភបំពាន។

ស្ថិតក្រោមច្បាប់ជាធរមាន បុគ្គលិកក្រុមហ៊ុនដែលរំលោភច្បាប់ ក្រមនេះ ឬគោលការណ៍របស់ក្រុមហ៊ុន អាចនឹងត្រូវប្រឈម ចំពោះការដាក់វិន័យ អាចឈានទៅដល់ និងរួមទាំងការបញ្ឈប់ពីការងារ។ បន្ថែមលើនេះទៀត ប្រធានណាម្នាក់ដែលជាអ្នកបញ្ជា ឬអនុញ្ញាតឲ្យមានការរំលោភបំពាន ឬបានដឹងពីការរំលោភបំពាន ហើយមិនរាយការណ៍វាឲ្យបានទាន់ពេលវេលានោះ អាចនឹងត្រូវប្រឈមនឹងការដាក់វិន័យផ្ទៃក្នុង។ី

ការប្តេជ្ញាចិត្តរបស់យើងចំពោះ

# ក្រមសីលធម៌ផ្នែកធុរកិច្ច



### ការអនុវត្តទៅតាមច្បាប់

សកម្មភាពក្រុមហ៊ុនរបស់យើងអនុលោមទៅតាមច្បាប់ បទបញ្ញត្តិ និងសកម្មភាពពង្រឹងច្បាប់ច្រើនឥតគណនានៅទូទាំងពិភពលោក។ វិសាលភាពច្បាប់និងបទបញ្ញត្តិ ដែលយើងធ្វើប្រតិបត្តិការពិតជាលំបាកខ្លាំងណាស់។ នៅក្រុមហ៊ុនយើង យើងយល់ថាការអនុវត្តទៅតាមច្បាប់ដែលមានជាធរមាន មានសារៈសំខាន់ដល់កាតព្វកិច្ចរបស់យើងចំពោះសហគមន៍យើង។ យើងប្តេជ្ញាចិត្តអនុវត្តទៅតាមច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលយើងអាចអនុវត្តបាន។

### ការប្រាស្រ័យទាក់ទងដោយយុត្តិធម៌ និងស្មោះត្រង់

យើងធ្វើអាជីវកម្មដោយស្មោះត្រង់និងសុចរិតភាព។ យើងប្រាស្រ័យទាក់ទងដោយយុត្តិធម៌ជាមួយនឹងអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង និយោជិត និយតករ និងអ្នកគ្រប់គ្នាដទៃផ្សេងទៀត។ យើងមិនកេងចំណេញដោយអយុត្តិធម៌ពីអ្នកផ្សេងតាមរយៈភាពមិនស្មោះត្រង់ ឬការធ្វើអាជីវកម្មដោយអយុត្តិធម៌ទេ។ យើងផលិតទំនិញ និងផ្តល់សេវាទាំងឡាយ ដែលយើងអាចមានមោទនភាព។
នៅពេលធ្វើទីផ្សារ យើងពិពណ៌នាពីផលិតផលនិងសេវាកម្មរបស់យើងទៅតាមមធ្យោបាយដែលយុត្តិធម៌និងត្រឹមត្រូវ។

### យើងគោរពតាមច្បាប់ស្តីពីការប្រឆាំងការជឿទុកចិត្ត និងការប្រកួតប្រជែង

បើទោះបីជាក្រុមហ៊ុនធ្វើការប្រកួតប្រជែងយ៉ាងស្វាហាប់នៅគ្រប់សកម្មភាពអាជីវកម្មទាំងអស់របស់ខ្លួនក៏ដោយ កិច្ចខិតខំនៅក្នុងទីផ្សារ ត្រូវតែធ្វើឡើងស្របទៅតាមច្បាប់ស្តីពីការប្រឆាំងការជឿទុកចិត្ត និងការប្រកួតប្រជែង។ បទល្មើសប្រឆាំងការជឿទុកចិត្តធ្ងន់ធ្ងរបំផុត គឺការ ព្រមព្រៀងរវាងដៃគូប្រកួតប្រជែងដែលកម្រិតពីសេចក្តីវិនិច្ឆ័យដោយឯករាជ្យនៃក្រុមហ៊ុនមួយ ដូចជាការព្រមព្រៀងកំណត់តម្លៃ ការដាក់កំហិតលើទិន្នផល ការគ្រប់គ្រងគុណភាពផលិតផល ឬបែងចែកទីផ្សារតំបន់ចែកចាយ និងផលិតផលសម្រាប់អតិថិជន។ អ្នកមិនត្រូវយល់ស្របជាមួយដៃគូប្រកួតប្រជែងណាម្នាក់ទៅលើប្រធានបទទាំងនេះឡើយ ដោយសារការព្រមព្រៀងទាំងនេះគឺតែងតែជារឿងមិនត្រឹមត្រូវតាមច្បាប់ និងបំពានទៅលើគោលនយោបាយរបស់ក្រុមហ៊ុន។

កិច្ចព្រមព្រៀងមិនត្រឹមត្រូវតាមច្បាប់ មិនចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬក៏ជាកិច្ចព្រមព្រៀងជាក់លាក់នោះទេ។ តុលាការអាចនឹងសម្អាងលើកិច្ចព្រមព្រៀងនានា ផ្អែកលើកិច្ចពិភាក្សាក្រៅផ្លូវការ ឬគ្រាន់តែជាការផ្លោះប្តូរយោបល់គ្នារវាងដៃគូប្រកួតប្រជែងស្តីពីព័ត៌មានដែលអាចនឹងឈានទៅរកកិច្ចព្រមព្រៀងពុំស្របច្បាប់ណាមួយ។

សូមប្រុងប្រយ័ត្ន មិនត្រូវពិភាក្សា ឬផ្លោះប្តូរយោបល់ជាមួយដៃគូប្រជែងរបស់យើងឡើយ (ទោះបីជានៅក្នុងកិច្ចប្រជុំក្រៅផ្លូវការក៏ដោយ) ទៅលើព័ត៌មានដែលមិនមែនជាកម្មសិទ្ធិសាធារណៈដូចជា៖

- តម្លៃបច្ចុប្បន្ន ឬអនាគត កំរិតប្រាក់ចំណេញ ឬយុទ្ធសាស្ត្រនៃការកំណត់តម្លៃ និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងតម្លៃ (ថ្លៃបន្ថែមការបញ្ចុះ និងការកាត់បន្ថយតម្លៃ)
- ព័ត៌មានស្តីពីតម្លៃលម្អិត (ឧ.ទា ពាក់ព័ន្ធនឹងធាតុចូលសំខាន់ៗ) ទាក់ទងទៅនឹងផលិតផលជាក់លាក់នានា។
- ព័ត៌មានយុទ្ធសាស្ត្រដែលបង្ហាញពីវិធីសាស្ត្ររបស់ក្រុមហ៊ុននៅក្នុងការចរចាជាមួយអតិថិជនអតិថិជនគោលដៅ ឬសកម្មភាពយុទ្ធសាស្ត្រប្រហាក់ប្រហែលគ្នានេះ។
- ព័ត៌មានលម្អិតអំពីការផ្តល់ជូនសេវាកម្មថ្មីៗដែលមានលក្ខណៈជាការប្រកួតប្រជែង ផែនការផលិតផល និងការធ្វើទីផ្សារ
- ព័ត៌មានពាក់ព័ន្ធនឹងសំណង ឬអត្ថប្រយោជន៍នានាសម្រាប់និយោជិត

តាមរយៈការប្រមូលផ្តុំដៃគូប្រកួតប្រជែងរួមគ្នា សមាគមពាណិជ្ជកម្មអាចលើកឡើងពីក្តីកង្វល់អំពីការប្រឆាំងការជឿទុកចិត្ត ទោះបីជាក្រុមទាំងនោះអាចនឹងបំពេញទៅតាមគោលដៅស្របច្បាប់ជាច្រើនយ៉ាងណាក៏ដោយ។ អ្នកត្រូវតែផ្តល់ដំណឹងដល់ផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋាន ឬផ្នែកនីតិកម្មមុនពេលចូលរួមជាមួយសមាគមពាណិជ្ជកម្ម ឬចូលរួមកិច្ចប្រជុំដែលអាចមានការពិភាក្សាគ្នាអំពីប្រធានបទដែលពាក់ព័ន្ធនឹងការប្រកួតប្រជែង។ ក្រុមហ៊ុនរបស់យើងមាននីតិវិធីលម្អិតដែលគ្រប់គ្រងលើស្ថានភាពទាំងនេះ។ ពិគ្រោះយោបល់អំពីវិធាននានាសម្រាប់ការប្រតិបត្តិតាមច្បាប់ស្តីពីការប្រកួតប្រជែងសម្រាប់ព័ត៌មានបន្ថែម។

សកម្មភាពផ្សេងទៀតដែលអាចលើកឡើងពីក្តីកង្វល់ក្រោមច្បាប់ស្តីពីការប្រឆាំងការជឿទុកចិត្ត និងការប្រកួតប្រជែង រួមមាន៖

- ការព្រមព្រៀងជាមួយអ្នកផ្គត់ផ្គង់ដើម្បីកំណត់ការលក់ទៅដល់ដៃគូប្រកួតប្រជែង
- ការគ្រប់គ្រងតម្លៃលក់បន្តនៅក្នុងប្រតិបត្តិការអាជីវកម្មជាមួយអ្នកចែកចាយ ឬអន្តរការីពាណិជ្ជកម្ម
- ការបដិសេធជារួមមិនព្រមធ្វើការដោះស្រាយជាមួយដៃគូប្រកួតប្រជែង ក្រុមហ៊ុនផ្គត់ផ្គង់ ឬអតិថិជន
- កិច្ចព្រមព្រៀងទិញ-លក់ផ្តាច់មុខដែលក្រុមហ៊ុនមួយតម្រូវឲ្យអតិថិជនទិញ ឬតម្រូវឲ្យក្រុមហ៊ុនផ្គត់ផ្គង់លក់ទៅឲ្យក្រុមហ៊ុននោះតែមួយគត់។
- កំណត់ដែននៃការទិញ-លក់ដែលអតិថិជន ឬក្រុមហ៊ុនផ្គត់ផ្គង់តម្រូវឲ្យអនុវត្ត ពោលគឺប្រសិនបើមានការទិញផលិតផលណាមួយ គឺត្រូវតែមានការទិញផលិតផលទីពីរផ្សេងទៀត។
- "ការកំណត់តម្លៃទាបពេក" នៅពេលដែលក្រុមហ៊ុនមួយផ្តល់ជូននូវការបញ្ចុះតម្លៃមួយដែលមានកម្រិតទាបជាងតម្លៃលក់ផលិតផលធម្មតា ក្នុងគោលបំណងរក្សានិរន្តភាពតម្លៃនោះឲ្យបានយូរដើម្បីកម្ចាត់ដៃគូប្រកួតប្រជែងចេញពីទីផ្សារ

វាមិនមានភាពច្បាស់លាស់នៅឡើយថាតើសកម្មភាពមួយគឺជាសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងឬយ៉ាងណានោះទេ ដូច្នេះសូមពិគ្រោះយោបល់ជាមួយផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានមន្ត្រីប្រតិបត្តិតាមច្បាប់ស្តីពីការប្រកួតប្រជែង ឬផ្នែកនីតិកម្មសម្រាប់ជាគោលការណ៍ណែនាំ។

**សំណួរ** មិត្តភក្តិរបស់ខ្ញុំម្នាក់នៅសាកលវិទ្យាល័យ ធ្វើការងារឲ្យគូប្រជែង របស់យើង។ កាលពីសប្តាហ៍មុន គាត់បានសួរខ្ញុំពីព័ត៌មានពាក់ព័ន្ធនឹងការប្រកួតប្រជែងសម្រាប់ផលិតផលដែលលក់ដាច់បំផុតរបស់យើង។ ខ្ញុំបានបញ្ចៀសពីបញ្ហានេះ ប៉ុន្តែខ្ញុំសូមស្នើសុំនូវគោលការណ៍ណែនាំខ្លះៗក្នុងករណីដែលបញ្ហានេះកើតឡើងម្តងទៀត។

**ចម្លើយ** អ្នកដាច់ខាតត្រូវតែកុំពិភាក្សាអំពីព័ត៌មានដែលពាក់ព័ន្ធនឹងការប្រកួតប្រជែងជាមួយនឹងដៃគូប្រកួតប្រជែងណាមួយរបស់ក្រុមហ៊ុន។ ទោះបីជាយើងដឹងច្បាស់ថា នៅក្នុងស្ថានភាព សង្គម ជួនកាលវាអាចមានភាពលំបាកនៅក្នុងការប្រព្រឹត្តិខ្លួនឲ្យបានសមស្រប ប៉ុន្តែអ្នកចាំបាច់ត្រូវតែពន្យល់មិត្តភក្តិរបស់អ្នកថា គោលនយោបាយ SEG ហាមឃាត់យ៉ាងតឹងរឹងមិនឲ្យអ្នកជជែកពិភាក្សាអំពីតម្លៃ ឬលក្ខខណ្ឌផ្សេងទៀតនៃការលក់ជាមួយដៃគូប្រកួតប្រជែងឡើយ។

## យើងមិនផ្តល់ជូន ឬទទួលសំណូកឡើយ

ការសូកប៉ាន់បង្កនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សហគមន៍ ហើយវាអាចបង្កនូវការខូចខាតធំទៅដល់ក្រុមហ៊ុន។
ការសូកប៉ាន់រួមមានការផ្តល់ជូន ការប្រគល់ ឬការទទួលវត្ថុមានតម្លៃអ្វីមួយដើម្បីមានឥទ្ធិពលលើការសម្រេចចិត្តអាជីវកម្ម ឬទទួលបានអត្ថប្រយោជន៍ផ្នែកអាជីវកម្មដោយមិនសមស្រប។

អ្នកមិនត្រូវអនុញ្ញាត ផ្តល់ជូន សន្យា ប្រគល់ ឬស្នើសុំ យល់ព្រមទទួល ឬទទួលយកសំណូកណាមួយជាដាច់ខាត ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី។

ការសូកប៉ាន់ មិនមែនសុទ្ធតែជាការផ្តល់ឲ្យជាសាច់ប្រាក់សុទ្ធនោះទេ។ សំណូកអាចមានជាច្រើនទម្រង់ដូចជា ការកម្សាន្ត ការបញ្ចុះតម្លៃដែលមិនសមស្រប ការជួលសមាជិកណាម្នាក់នៃគ្រួសារមួយដែលអ្នកព្យាយាមមានឥទ្ធិពលទៅលើឬសូម្បីតែការផ្តល់វិភាគទានសប្បុរសធម៌ដើម្បីមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកអាជីវកម្មមួយ។ សំណូកអាចជាអ្វីមួយដែលមានតម្លៃសម្រាប់អ្នកទទួល។ ម្យ៉ាងទៀត បរិមាណសំណូកដែលបានផ្តល់ជូន ឬចំណាយ គឺមិនមានការពាក់ព័ន្ធគ្នាឡើយ។ ប្រសិនបើគេស្នើសុំឲ្យអ្នកធ្វើការបង់ប្រាក់ ឬអ្វីមួយដែលមានតម្លៃដែលបង្កើតបានជាសំណូក ត្រូវរាយការណ៍ពីបញ្ហានេះទៅដល់ផ្នែកនីតិកម្មជាបន្ទាន់។

ប្រទេសភាគច្រើនមានច្បាប់ដែលហាមឃាត់ការសូកប៉ាន់មន្ត្រីរដ្ឋាភិបាល។ បុគ្គលិករបស់ស្ថាប័នរដ្ឋាភិបាល (ដូចជាក្រុមហ៊ុនទូរគមនាគមន៍ដែលជាកម្មសិទ្ធិរបស់រដ្ឋ ក្រុមហ៊ុនថាមពល ឬមន្ទីរពេទ្យ) ត្រូវបានចាត់ទុកជាមន្ត្រីរបស់រដ្ឋាភិបាល ស្ថិតក្រោមច្បាប់ស្តីពីការប្រឆាំងអំពើស៊ីសំណូក។ ប្រទេសជាច្រើន ក៏ហាមឃាត់ការប្រព្រឹត្តអំពើស៊ីសំណូករបស់បុគ្គល ឬក្រុមហ៊ុនឯកជនផងដែរ។ ក្រុមហ៊ុនហាមឃាត់យ៉ាងតឹងរឹងលើការប្រព្រឹត្តអំពើស៊ីសំណូកគ្រប់កាលៈទេសៈទាំងអស់ មិនថាពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាល បុគ្គលឯកជន ឬក្រុមហ៊ុនផ្សេងទៀតក៏ដោយ។  ការបំពានទៅនឹងច្បាប់ស្តីពីការប្រឆាំងការស៊ីសំណូក អាចនឹងនាំមកនូវផលវិបាកធ្ងន់ធ្ងរសម្រាប់អ្នក

និងសម្រាប់ក្រុមហ៊ុនរបស់យើង រួមមានការខូចខាតកេរ្តិ៍ឈ្មោះ ប្រាក់ពិន័យច្រើនសន្ធឹកសន្ធាប់ និងជាប់ពន្ធនាគារសម្រាប់បុគ្គលម្នាក់ៗ។ អ្នកគប្បីចៀសវាងសកម្មភាពទាំងឡាយណាដែលមិនត្រឹមត្រូវមិនសមរម្យ។

ក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះការស៊ីសំណូកដែលបានប្រព្រឹត្តដោយភាគីទីបីដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់ក្រុមហ៊ុន។ យើងត្រូវតែប្រុងប្រយ័ត្ននៅក្នុងការជ្រើសរើសដៃគូអាជីវកម្ម និងពិនិត្យមើលឲ្យបានត្រឹមត្រូវដើម្បីធានាថា ពួកគេមិនប្រព្រឹត្តអំពើស៊ីសំណូកក្នុងនាមពួកយើងនោះឡើយ។ យើងគោរពតាមនីតិវិធីរបស់ក្រុមហ៊ុននៅពេលបង្កើតទំនាក់ទំនងជាមួយភាគីទីបី។ និងមិនត្រូវព្រងើយកន្តើយចំពោះសញ្ញាព្រមាននានាដែលដៃគូអាជីវកម្មអាចនឹងមានការពាក់ព័ន្ធនឹងសកម្មភាពល្មើសច្បាប់ ឬសកម្មភាពអសីលធម៌នានា។ ប្រសិនបើអ្នកដឹងថា ដៃគូអាជីវកម្មណាមួយរបស់យើងកំពុង ឬអាចនឹង កំពុងផ្តល់ ឬទទួលសំណូក សូមកុំចូលរួមជាមួយ ហើយត្រូវផ្តល់ព័ត៌មានដល់ផ្នែកប្រតិបត្តិតាមមូលដ្ឋានរបស់អ្នក នាយកគ្រប់គ្រងផ្នែកបង្កាអំពើស៊ីសំណូក ឬផ្នែកនីតិកម្មភ្លាមៗតាមដែលអាចធ្វើទៅបាន។

និយាយរួម ធុរកិច្ចតូចតាចដូចជា ការចំណាយសមរម្យសម្រាប់អាហារដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្ម ឬការអនុវត្តកិច្ចសន្យាគឺមិនត្រូវបានហាមឃាត់ឡើយ។ ប៉ុន្តែ ច្បាប់គ្រប់គ្រងលើការផ្តល់ជូនអាហារ និងគារវកិច្ចការងារទៅដល់មន្ត្រីរដ្ឋាភិបាល គឺមានភាពស្មុគស្មាញ ហើយមានលក្ខណៈខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយ។ ដើម្បីធានាបាននូវការប្រតិបត្តិតាម អ្នកត្រូវតែទទួលបាននូវការអនុញ្ញាតពីនាយកគ្រប់គ្រងផ្នែកបង្ការការស៊ីសំណូក និងផ្នែកនីតិកម្មមុនពេលផ្តល់ជូនដល់មន្ត្រីរដ្ឋាភិបាលនូវអាហារ អំណោយ ការកម្សាន្ត ការចំណាយលើការធ្វើដំណើរ ឬការធ្វើគារវកិច្ចប្រភេទផ្សេងទៀត។ អ្នកក៏ត្រូវរក្សានូវកំណត់ត្រាឲ្យបានច្បាស់លាស់អំពីការចំណាយទាំងនេះ។

**សំណួរ** តើមានសញ្ញាព្រមានណាមួយដែលអាចនឹងបង្ហាញថា ដៃគូ ឬភ្នាក់ងារអាជីវកម្មរបស់យើង អាចនឹងមានការពាក់ព័ន្ធទៅនឹងការស៊ីសំណូកដែរឬទេ?

**ចម្លើយ** បាទ/ចាស មាន "សញ្ញាព្រមាន" ថាអ្នកគួរតែមានការប្រុងប្រយ័ត្ននៅក្នុងការធ្វើអាជីវកម្មរបស់អ្នកជាមួយដៃគូ ឬភ្នាក់ងារអាជីវកម្មណាមួយ រួមមាន៖

- ទំនាក់ទំនងអាជីវកម្ម ត្រូវធ្វើឡើងនៅក្នុងប្រទេសដែលល្បីក្នុងរឿងស៊ីសំណូក និងអំពើពុករលួយ។
- ដៃគូ ឬភ្នាក់ងារអាជីវកម្ម មិនមានជំនាញដែលជាលក្ខខណ្ឌតម្រូវក្នុងការអនុវត្តការងារ ឬផ្តល់ជូនសេវាកម្មតាមការស្នើសុំ។
- ដៃគូ និងភ្នាក់ងារអាជីវកម្ម ស្នើសុំនូវលក្ខខណ្ឌបង់ប្រាក់ខុសពីធម្មតាដូចជាថ្លៃបង់មុនក្នុងចំនួនដ៏ច្រើន ឬស្នើសុំឲ្យធ្វើការបង់ប្រាក់នៅក្នុងគណនី ឬឲ្យទៅបុគ្គលណាម្នាក់នៅក្នុងប្រទេសផ្សេងទៀត។
- ដៃគូ ឬភ្នាក់ងារអាជីវកម្ម បដិសេធមិនយល់ព្រមចំពោះបទប្បញ្ញត្តិស្តីពីការប្រឆាំងការស៊ីសំណូកនៅក្នុងកិច្ចសន្យារបស់យើង។
- ដៃគូ និងភ្នាក់ងារអាជីវកម្ម មានការពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាមួយនឹងសិទ្ធិសម្រេចទៅលើអាជីវកម្មរបស់យើង។

## អំណោយ និងការកែកម្សាន្ត

នៅពេលអ្នកចូលរួមនៅក្នុងសេចក្តីសម្រេចចិត្តអាជីវកម្មក្នុងនាមក្រុមហ៊ុន ការសម្រេចចិត្តរបស់អ្នកត្រូវតែគ្មានការបង្ខិតខង្ខំ និងផ្អែកលើការវិនិច្ឆ័យច្បាស់លាស់។ មិនត្រូវទទួលយកអំណោយ ឬអត្ថប្រយោជន៍ផ្សេងទៀតឡើយ ប្រសិនបើអំណោយទាំងនោះ អាចប៉ះពាល់ដល់ការវិនិច្ឆ័យ ឬការសម្រេចចិត្តផ្នែកអាជីវកម្មរបស់អ្នក។

អ្នកមិនត្រូវស្នើសុំអំណោយ ការកម្សាន្ត ឬគារវកិច្ចអាជីវកម្មផ្សេងទៀតពីអ្នកដែលធ្វើអាជីវកម្មជាមួយក្រុមហ៊ុន។ អំណោយជាប្រាក់សុទ្ធ ឬមានតម្លៃសមមូលជាទឹកប្រាក់ដូចជាប័ណ្ណ អំណោយក្នុងចំនួនទឹកប្រាក់ណាមួយ ត្រូវបានហាមឃាត់ បើគ្មានការយល់ព្រមជាមុនជាយលក្ខណ៍អក្សរទេនោះ។ ការប្រគល់ ឬទទួលអំណោយ ឬការកែកម្សាន្តណាមួយដែលមានលក្ខខណៈជាសំណូក ឬប្រាក់សងគុណ ត្រូវបានហាមឃាត់។ យើងក៏មិនដែលផ្តល់ជូន ឬទទួលយកនូវការកម្សាន្ត ឬអំណោយណាមួយដែលមិនស្របទៅនឹងស្តង់ដារបស់ក្រុមហ៊ុនអំពីការគោរពចំពោះបុគ្គល។

អំណោយដែលផ្តល់ជូនដោយឯកឯង និងការធ្វើគារវកិច្ចអាជីវកម្ម រួមមានអាហារនិងការកម្សាន្ត អាចអនុញ្ញាតឲ្យផ្តល់ជូនបាន ប្រសិនបើរបស់ទាំងអស់នេះមានលក្ខណៈសាមញ្ញធម្មតា និងមានការទទួលយកជាទូទៅដោយការធ្វើគារវកិច្ចអាជីវកម្ម ដែលមិនមានតម្លៃច្រើនជ្រុល និងមិន ញឹកញាប់ពេក ហើយការផ្តល់ជូន និងទទួលយកអំណោយនេះគឺគ្មានជាប់កាតព្វកិច្ចអាជិវកម្មនោះទេ។ អំណោយនានា ដែលមានតម្លៃខ្ពស់ ឬមានលក្ខណៈខុសប្រក្រតី មិនត្រូវផ្តល់ជូន និងទទួលយកដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីនាយកគ្រប់គ្រងការបង្ការការសូកប៉ាន់នោះទេ។

ក្រុមហ៊ុនផ្គត់ផ្គង់ និងអតិថិជនរបស់យើងភាគច្រើន មានគោលនយោបាយផ្តល់អំណោយនិងការកម្សាន្តផ្ទាល់ខ្លួនរបស់ពួកគេដែរ។ ត្រូវមានការប្រុងប្រយ័ត្នមិនត្រូវផ្តល់ឬទទួលយកអំណោយ ឬការកម្សាន្តដែលដឹងថាប៉ះពាល់ដល់គោលនយោបាយនៃការផ្តល់អំណោយ និងការកម្សាន្តរបស់ក្រុមហ៊ុនដទៃឡើយ។

**សំណួរ** ចង់ផ្តល់កាដូដល់អតិជនដែលល្អបំផុតរបស់យើងម្នាក់ដើម្បីថ្លែងអំណរគុណ។ ខ្ញុំមានសំបុត្រចូលទស្សនារោងមហោស្រពមួយចំនួន ដែលខ្ញុំគិតថា គាត់នឹងពេញចិត្ត ប៉ុន្តែខ្ញុំគិតថាវាគឺជាអំពើដែលល្មើសនឹងគោលនយោបាយរបស់ក្រុមហ៊ុនគាត់ដើម្បីទទួលយកសំបុត្រទាំងនេះ។ ប្រសិនបើគាត់គិតថាមិនបានប្រព្រឹត្តខុសចំពោះគោលនយោបាយនេះ និងមានបំណងទៅទស្សនាមែន តើខ្ញុំអាចផ្តល់សំបុត្រនោះដល់គាត់បានដែរឬទេ?

**ចម្លើយ** មិនបានទេ។ ប្រសិនបើអ្នកដឹងថា ការផ្តល់កាដូនឹងបំពានលើគោលនយោបាយក្រុមហ៊ុននៃអ្នកទទួលកាដូ អ្នកមិនចាំបាច់ផ្តល់កាដូនោះទេ។ ប្រសិនបើអ្នកមិនច្បាស់ ថាតើមានការអនុញ្ញាតឲ្យទទួលយកកាដូដែរឬអត់នោះ អ្នកគួរសាកសួរអំពីបញ្ហានេះ។ យើងគ្រាន់តែចង់ឲ្យមនុស្សដទៃគោរពស្តង់ដារបស់យើង ហើយយើងនឹងគោរពស្តង់ដារបស់ពួកគេដែរ។

## ការដោះស្រាយបញ្ហាជាមួយរដ្ឋាភិបាល

វិធានការខុសគ្នា — និងជាទូទៅមានភាពតឹងរឹងជាងនេះ — អនុវត្តចំពោះការដោះស្រាយបញ្ហាជាមួយភ្នាក់ងារ និងមន្ត្រីរដ្ឋាភិបាលនៅក្នុងទិដ្ឋភាពមួយចំនួននៃការប្រកបអាជីវកម្ម រួមបញ្ចូលទាំងអំណោយ និងការកម្សាន្ត ការជួលបុគ្គលិក និងការទំនាក់ទំនងលក្ខណៈធម្មតាជាមួយមនុស្សដទៃផ្សេងទៀត។ អ្វីដែលអាចទទួលយកបាននៅក្នុងបរិយាកាសអាជីវកម្មពាណិជ្ជកម្ម អាចនឹងពុំអាចទទួលយកបាននៅក្នុងការដោះស្រាយបញ្ហាជាមួយរដ្ឋាភិបាល។

មានច្បាប់ជាច្រើនដែលគ្រប់គ្រងលើការផ្តល់អំណោយ អាហារ ការកម្សាន្ត ការធ្វើដំណើរ និងអត្ថប្រយោជន៍ផ្សេងទៀតជូនដល់មន្ត្រីនិងបុគ្គលិករដ្ឋាភិបាល។ អ្នកអាចត្រូវបានហាមឃាត់មិនឲ្យផ្តល់អំណោយ ការកម្សាន្ត ឬអ្វីផ្សេងទៀតដែលមានតម្លៃជូនដល់មន្ត្រីឬបុគ្គលិករដ្ឋាភិបាល ឬសមាជិកគ្រួសាររបស់ពួកគេ ពាក់ព័ន្ធនឹងអាជីវកម្ម ក្រុមហ៊ុន ដោយគ្មានការឯកភាពជាលាយលក្ខណ៍អក្សរពីនាយកគ្រប់គ្រង់ការបង្ការការសូកប៉ាន់ និងផ្នែកនីតិកម្មរបស់អ្នក។ វិធានពិសេសនានាក៏អនុវត្តផងដែរចំពោះការជួលមន្ត្រីរដ្ឋាភិបាល ឬសមាជិកក្រុមគ្រួសាររបស់ពួកគេឲ្យបម្រើការងារនៅក្នុងក្រុមហ៊ុនរបស់យើង។ ប្រសិនបើអ្នកកំពុងពិចារណាក្នុងការពង្រីកបន្ថែមការផ្តល់ឱកាសការងារដល់មន្ត្រីរដ្ឋាភិបាល ឬសមាជិកក្រុមគ្រួសារមន្ត្រីរដ្ឋាភិបាលណាម្នាក់ អ្នកត្រូវធ្វើការទំនាក់ទំនងជាមុនទៅកាន់ផ្នែកនីតិកម្មដើម្បីធានាថា អ្នកអនុវត្តទៅតាមច្បាប់ជាធរមាន។

បន្ថែមលើនេះ ចំពោះរាល់ការប្រាស្រ័យទាក់ទងទាំងអស់របស់យើងជាមួយមន្ត្រីនិងបុគ្គលិករដ្ឋាភិបាល វាជាការចាំបាច់ដែលយើងធានាថាសេចក្តីថ្លែងការណ៍ និងការទំនាក់ទំនងទាំងអស់ ត្រូវបានធ្វើឡើងដោយស្មោះត្រង់ ពេញលេញ និងច្បាស់លាស់។ យើងក៏ត្រូវកត់ត្រាឲ្យបានត្រឹមត្រូវផងដែរអំពីពេលវេលា ថ្លៃចំណាយ និងថ្លៃបន្ទុកនានាទៅក្នុងគណនីដែលសមស្រប។ ហើយនៅត្រង់ចំណុចណាដែលអាចអនុវត្តបាន យើងត្រូវធានាថា យើងអនុត្តតាមរាល់លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងព័ត៌មានសម្ងាត់របស់រដ្ឋាភិបាល និងព័ត៌មានរសើប។

## ជំនួញអន្តរជាតិ

ក្រុមហ៊ុនរបស់យើងប្រកបអាជីវកម្មនៅជុំវិញពិភពលោក ហើយយើងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដែលគ្រប់គ្រងលើរបៀបធ្វើអាជីវកម្មរបស់យើងនៅក្រៅប្រទេសទាំងអស់ រួមទាំងរបៀប ដែលយើងនាំចូលនិងនាំចេញផលិតផលផងដែរ។ យើងក៏អនុវត្តតាមច្បាប់និងបទប្បញ្ញត្តិដែលហាមឃាត់យើងពីការប្រកបអាជីវកម្មនៅក្នុងប្រទេសមួយចំនួន ឬជាមួយបុគ្គល ឬស្ថាប័នជាក់លាក់ ណាមួយផងដែរ។ ប្រសិនបើទំនួលខុសត្រូវរបស់អ្នក រួមបញ្ចូលទាំង ការលក់ ឬការផ្ទេរទំនិញ សេវាកម្ម ឬបច្ចេកវិទ្យារវាងប្រទេសនឹងប្រទេស បើទោះបីជានៅក្នុងចំណោម ឬរវាងក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ SEG ក៏ដោយ ក៏អ្នកត្រូវតាមដានព័ត៌មានអំពីច្បាប់និងគោលនយោបាយក្រុមហ៊ុននៅក្នុងផ្នែកនេះ និងត្រូវធ្វើការសាកសួរផ្នែកនីតិកម្ម ប្រសិនបើអ្នកមានសំណួរណាមួយ។

## ការធ្វើជំនួញនៅក្នុងស្រុក

យើងអនុវត្តតាមច្បាប់មូលប័ត្រជាធរមានទាំងអស់។ អ្នកមិនត្រូវទិញ ឬលក់មូលបត្ររបស់ក្រុមហ៊ុននៅពេលដែលអ្នកកាន់កាប់ព័ត៌មាន មិនមែនសាធារណៈជាសារវ័ន្ត (ពេលខ្លះគេហៅថា "ព័ត៌មានផ្ទៃក្នុង") អំពីក្រុមហ៊ុន។ នេះក៏ហៅបានម្យ៉ាងទៀតថា "ការធ្វើជំនួញផ្ទៃក្នុង" ហើយវាគឺជារឿងខុសច្បាប់។ ព័ត៌មានផ្ទៃក្នុង គឺជាព័ត៌មានដែលអ្នកវិនិយោគគិតថាមានសារៈសំខាន់ក្នុងការធ្វើការសម្រេចចិត្តថាតើត្រូវទិញឬលក់មូលបត្រ។ ឧទាហរណ៍នានា រួមមានលទ្ធផលហិរញ្ញវត្ថុ កិច្ចសន្យាថ្មី ឬកិច្ចសន្យាដែលមិនផ្តល់ជូន ព័ត៌មានផលិតផល លទ្ធផលលក់ និងការផ្លាស់ប្តូរបុគ្គលិកសំខាន់ៗ។ ការបញ្ជូនបន្តព័ត៌មាននេះទៅកាន់អ្នកណាម្នាក់ដែលអាចនឹងទិញ ឬលក់មូលបត្រ ត្រូវបានគេហៅថា "ការផ្តល់ព័ត៌មានសម្ងាត់" និងជាអំពើខុសច្បាប់។ ការហាមឃាត់នេះ អនុវត្តចំពោះមូលបត្ររបស់ក្រុមហ៊ុន SEG និងចំពោះមូលបត្ររបស់ក្រុមហ៊ុនដទៃផ្សេងទៀត ប្រសិនបើអ្នកបានដឹងអំពីព័ត៌មានមិនមែនសាធារណៈជាសារវ័ន្តស្តីពីក្រុមហ៊ុនផ្សេង (ដូចជា ក្រុមហ៊ុនផ្គត់ផ្គង់ និងអតិថិជនរបស់យើង) នៅក្នុងរយៈពេលនៃកាតព្វកិច្ចរបស់អ្នកសម្រាប់ក្រុមហ៊ុន SEG។

**សំណួរ** អ្នកដឹងតាមរយៈការងាររបស់អ្នកថា ក្រុមហ៊ុនរបស់យើងទំនងជានឹងទទួលយកនូវក្រុមហ៊ុនបច្ចេកវិទ្យាដ៏គួរឲ្យចាប់អារម្មណ៍មួយនារយៈពេលពីរបីខែខាងមុខនេះ។ ដោយមិនបានប្រាប់គាត់ឲ្យបានពិស្តារទេ អ្នកបានផ្តល់យោបល់ឲ្យបងប្រុសរបស់អ្នកថាគាត់អាចនឹងពិចារណាទិញភាគហ៊ុននៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យានោះ។ តើធ្វើបែបនេះមានបញ្ហាអ្វីទេ?

**ចម្លើយ** បាទ/ចាស ពិតជាមានបញ្ហា។ ថ្វីបើអ្នកមិនបានផ្តល់ដល់បងប្រុសរបស់អ្នកឲ្យបានពិស្តារណាមួយក៏ដោយ ក៏អ្នកអាចនឹងត្រូវជាប់ទាក់ទងក្នុង “ការផ្តល់ពត៌មានសម្ងាត់” ដោយផ្តល់ជាយោបល់ថាឲ្យគាត់គួរទិញភាគហ៊ុននៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យា។

**សំណួរ** ពេញមួយរយៈពេលនៃការងាររបស់ខ្ញុំ ខ្ញុំបានឮថាមានសាជីវកម្មមួយនៃសាជីវកម្មដែលជាអតិថិជនរបស់យើងនឹងប្រកាសក្នុងពេលឆាប់ៗនេះថា គេនឹងទទួលបានកិច្ចសន្យា ដ៏ធំមួយ។ តើខ្ញុំអាចទិញភាគហ៊ុននៅក្នុងក្រុមហ៊ុនរបស់គេបានដែរឬទេ?

**ចម្លើយ** មិនបានទេ ដោយហេតុថារឿងនេះពាក់ព័ន្ធដល់ព័ត៌មានផ្ទៃក្នុងរបស់អតិថិជន ដែលអ្នកទទួលបានក្នុងអំឡុងនៃការបំពេញការងាររបស់អ្នកជាមួយក្រុមហ៊ុនរបស់យើង។

## វិភាគទាននិងសកម្មភាពនយោបាយ

យើងអនុវត្តទៅតាមច្បាប់ទាំងអស់ ដែលគ្រប់គ្រងទៅលើការចូលរួមរបស់ក្រុមហ៊ុននៅក្នុងកិច្ចការនយោបាយ ដោយរាប់បញ្ចូលទាំងច្បាប់ទាំងនោះដែលគ្រប់គ្រងទៅលើករណី និងនិតិវិធីដែលយើងចូលវិភាគទានចំពោះបេក្ខជន និងគណៈបក្សនយោបាយ និងស្វះស្វែងឲ្យមានឥទ្ធិពលទៅលើសកម្មភាពរបស់រដ្ឋាភិបាល។ច្បាប់នៅក្នុងផ្នែកនេះមានលក្ខណៈស្មុគស្មាញ ហើយវានមានលក្ខណៈខុសៗគ្នាទៅតាមទីតាំងផ្សេងៗគ្នា ដែលក្រុមហ៊ុនយើងធ្វើប្រតិបត្តិការ។ អ្នកត្រូវតែពិគ្រោះជាមួយផ្នែកទំនាក់ទំនងប្រតិបត្តិតាមនៅនឹងកន្លែងរបស់អ្នក ប្រធានគ្រប់គ្រងផ្នែកបង្ការការសូកប៉ាន់ និងផ្នែកនីតិកម្មមុននឹងប្រើប្រាស់ធនធានរបស់ក្រុមហ៊ុនយើង នៅក្នុងការគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយ ឬមុនពេលអ្នកមានទំនាក់ទំនងដោយផ្ទាល់ ឬប្រយោលជាមួយនឹងមន្ត្រីសាធារណៈក្នុងនាមក្រុមហ៊ុនរបស់យើង ដើម្បីមានឥទ្ធិពលលើការងារនិតិកម្ម ឬសកកម្មភាព រដ្ឋាភិបាល។

**សំណួរ** ប្រធានគ្រប់គ្រងបានសុំខ្ញុំឲ្យផ្តល់វិភាគទានទៅដល់បេក្ខជននយោបាយ។ គាត់ប្រាប់ខ្ញុំថា ក្រុមហ៊ុននឹង “ផ្តល់សិទ្ធិឲ្យអ្នកសម្រេច។” តើការធ្វើបែបនេះត្រូវបានអនុញ្ញាតទេ?

**ចម្លើយ** ទេនេះមិនត្រូវបានអនុញ្ញាតទេ។អ្នកគួរតែបដិសេធចំពោះសំណើនេះ ហើយរាយការណ៍បញ្ហានេះដោយប្រើប្រាស់ធនធានដូចដែលបានរៀបរាប់នៅក្នុងក្រមនេះ។

ការប្តេជ្ញាចិត្តរបស់យើងចំពោះ

# ក្រុមហ៊ុន



## គណនេយ្យនិងកំណត់ត្រាទាំងឡាយរបស់ក្រុមហ៊ុន

នៅក្រុមហ៊ុនយើង យើងបំពេញសំណុំឯកសារអាជីវកម្មទាំងអស់បានយ៉ាងត្រឹមត្រូវ ពិតប្រាកដ និងទាន់ពេលវេលា ក្នុងនោះរាប់បញ្ចូលទាំងរបាយការណ៍ធ្វើដំណើរនិងចំណាយទាំងអស់ផងដែរ។ យើងរៀបចំដោយពេញលេញ យុត្តិធម៌ ត្រឹមត្រូវ និងទាន់ពេលបញ្ចេញទៅក្នុងរបាយការណ៍ ហើយឯកសារទាំងឡាយដែលយើងបានដាក់ជូនដល់និយតកររដ្ឋាភិបាល រួមទាំងរបាយការណ៍ហិរញ្ញវត្ថុតាមពេលវេលកំណត់ជាក់លាក់ផងដែរ។ នៅពេលសមស្រប ឯកសារទាំងឡាយត្រូវតែទទួលបានករអនុញ្ញាតត្រឹមត្រូវ។ យើងកត់ត្រាសកម្មភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយអនុវត្តទៅតាមច្បាប់ដែលមានជាធរមាន និងការអនុវត្តផ្នែកគណនេយ្យ។ យើងមិនត្រូវធ្វើឲ្យមានកំហុស ឬបញ្ចូលទិន្នន័យច្រឡំទៅក្នុងកមណត់ត្រារបស់ក្រុមហ៊ុននោះទេ ហើយមិនត្រូវលុបព័ត៌មានចេញពីក្នុងកំណត់ត្រារបស់យើង ដែលតម្រូវឲ្យកត់ត្រាឡើយ។

យើងក៏ត្រូវតែរក្សាកំណត់ត្រារបស់ក្រុមហ៊ុនយើងឲ្យបានយូរអង្វែងផងដែរ និងទៅតាមលក្ខណៈតម្រូវដោយច្បាប់និងគោលការណ៍របស់ក្រុមហ៊ុន។

**សំណួរ** នៅក្នុងសប្តាហ៍ចុងក្រោយក្នុងរយៈពេលធ្វើរបាយការណ៍ប្រចាំត្រីមាស។ ប្រធានរបស់ខ្ញុំចង់បញ្ជាក់ឲ្យប្រាកដពីតួលេខរបស់យើងប្រចាំត្រីមាស ដូច្នេះហើយ គាត់ក៏បានសុំឲ្យខ្ញុំកត់ត្រាការលក់ បើទោះបីជាការរៀបចំឯកសារនឹងមិនត្រូវបានបញ្ចប់ក៏ដោយ។ ខ្ញុំគិតថានេះវានឹងមិនប៉ះពាល់នរណាម្នាក់ឡើយ — ប្រសិនបើខ្ញុំធ្វើទៅតាមអ្វីដែលគាត់ប្រាប់។

**ចម្លើយ** ទេ អ្នកមិនគួរធ្វើទេ។ ប្រសិនបើគ្មានចែងនៅក្នុងគោលនយោបាយទេនោះការលក់អាចត្រូវរាយការណ៍បានតែនៅក្រោយពេលកិច្ចសន្យាត្រូវបានបញ្ចប់សព្វគ្រប់ជាមុនសិន។ អ្នកគួរតែរាយការណ៍បញ្ហានេះទៅកាន់ផ្នែកនិតិកម្ម ផ្នែកគណនេយ្យ ឬទៅកាន់ផ្នែកពាក់ព័ន្ធទាំងឡាយដូចបានកំណត់នៅក្នុងក្រមនេះ។

**សំណួរ** មិត្តរួមការងារម្នាក់បានសុំឲ្យខ្ញុំលុបអ៊ីម៉ែលជាក់លាក់មួយចោល ដោយសារតែគាត់ជឿថា ពាក្យបណ្តឹងមួយអាចនឹងត្រូវធ្វើឡើង ហើយអ៊ីម៉ែលទាំងឡាយអាចនឹងត្រូវធ្វើឲ្យខ្មាសគេ។ តើអ្នកអាចនឹងធ្វើបែបនេះបានទេ?

**ចម្លើយ** ទេ វានឹងរំលោភដល់គោលនយោបាយរបស់យើង —ហើយអាចនឹងរំលោភដល់ច្បាប់ផងដែរ —ទាក់ទងទៅដល់ការរក្សាទុកកំណត់ត្រាដែលពាក់ព័ន្ធចំពោះទំនាស់ផ្លូវច្បាប់។ អ្នកត្រូវរាយការណ៍បញ្ហានេះ ដោយប្រើប្រាស់និតិវិធីដូចដែលបានកំណត់នៅក្នុងក្រមនេះ។

## ជម្លោះផលប្រយោជន៍

នៅក្រុមហ៊ុនរបស់យើង យើងម្នាក់ៗមានការទទួលខុសត្រូវទៅលើការធ្វើសេចក្តីសម្រេចចិត្ត ដែលជះឥទ្ធិពលមដល់ក្រុមហ៊ុន ផ្អែកទៅលើផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់ក្រុមហ៊ុន ឯករាជ្យពីឥទ្ធិពលនានាពីខាងក្រៅ។ ជម្លោះផលប្រយោជន៍កើតឡើងនៅពេលណាបុគ្គលម្នាក់មានសក្តានុពលជ្រៀតជ្រែកមកលើសមត្ថភាពបំពេញការងាររបស់អ្នកសម្រាប់ក្រុមហ៊ុនរបស់យើងមិនលម្អៀងនិងប្រកបដោយប្រសិទ្ធិភាព។ កាតព្វកិច្ចរបស់យើងគឺត្រូវប្រកបអាជីវកម្មរបស់ក្រុមហ៊ុនយើងប្រកបដោយក្រមសីលធម៌និងភាពស្មោះត្រង់ រួមទាំងការដោះស្រាយស្ថានភាពត្រឹមត្រូវ ដែលអាចបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ ឬដែលថែមទាំងបង្កើតឲ្យមានទស្សនក្នុងចំណោមអ្នកផ្សេង ដែលនឹងឈានដល់ទំនាស់អាចនឹងកើតឡើង។ ក្នុងករណីអ្នកជឿថា អ្នកមានទំនាស់ ឬក្នុងករណីអ្នកដឹងអំពីទំនាស់ ដែលនឹងអាចកើតឡើងនោះ អ្នកគួរតែជម្រាបវាទៅកាន់ប្រធានរបស់អ្នក ផ្នែកទំនាក់ទំនងប្រតិបត្តិតាមនៅនឹងកន្លែងរបស់អ្នក ឬផ្នែកនិតិកម្មភ្លាម។

ខណៈដែលវាមិនអាចរៀបរាប់បានឲ្យគ្រប់ស្ថានភាព ដែលទំនាស់ផលប្រយោជន៍អាចនឹងកើតឡើងនោះ ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃប្រភេទស្ថានភាព ដែលអាចនឹងបង្កើតឲ្យមានទំនាស់ហើយដែលត្រូវតែជូនដំណឹង៖

- **ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ** នៅក្នុងក្រុមហ៊ុនដែលប្រកបអាជីវកម្ម ឬស្វែងរកប្រកបអាជីវកម្មជាមួយក្រុមហ៊ុនរបស់យើង ក្នុងនោះមាន អតិថិជន ឬក្រុមហ៊ុនផ្គត់ផ្គង់ ឬ នៅក្នុងគូប្រជែងរបស់យើង។ យើងមិនត្រូវអនុញ្ញាតឲ្យការវិនិយោគផ្នែកហិរញ្ញវត្ថុជាលក្ខណៈបុគ្គលរបស់យើងដើម្បីមានឥទ្ធិពលលើ ឬហាក់ដូចជាមានឥទ្ធិពលលើ ការវិនិច្ឆ័យដោយឯករាជ្យរបស់យើងក្នុងនាមក្រុមហ៊ុនយើងឡើយ។ ករណីនេះអាចនឹងកើតឡើងនៅក្នុងរូបភាពជាច្រើន ប៉ុន្តែទំនាស់ដែលទំនងជានឹងកើតឡើងច្រើនជាងគេ គឺនៅពេលដែលអ្នកមានការវិនិយោគនៅក្នុងក្រុមហ៊ុនជាគូប្រជែង ក្រុមហ៊ុនផ្គត់ផ្គង់ ឬអតិថិជន និងការសម្រេចចិត្តរបស់អ្នកក្នុងនាមក្រុមហ៊ុនរបស់យើងអាចនឹងផ្តល់ផលប្រយោជន៍ដល់ភាគីទីបីនោះ។
- **ការធ្វើការងារ** ជាមួយ ឬក្នុងនាមជាអ្នកផ្តល់ប្រឹក្សាដល់ គូប្រជែងក្រុមហ៊ុនរបស់យើង ក្រុមហ៊ុនផ្គត់ផ្គង់ អតិថិជន ឬដៃគូអាជីវកម្មដទៃផ្សេងទៀត។
- **ដឹកនាំអាជីវកម្មក្រុមហ៊ុនរបស់យើងទៅក្រុមហ៊ុនផ្គត់ផ្គង់ ភ្នាក់ងារ ក្រុមហ៊ុនចែកចាយ ឬក្រុមហ៊ុនម៉ៅការ** ណាមួយដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ ឬមិនផ្ទាល់ដោយខ្លួនអ្នកផ្ទាល់ សមាជិកគ្រួសាររបស់អ្នក ឬមិត្តជិតស្និទ្ធរបស់អ្នក។
- **ឱកាសអាជីវកម្មនានា** មានន័យថាកេងយកផលប្រយោជន៍ផ្ទាល់ខ្លួនពីឱកាសអាជីវកម្ម ដែលអ្នកបានដឹងដោយសារតែការងាររបស់អ្នកនៅក្នុងក្រុមហ៊ុនរបស់យើង។
- ការជួល ការដំឡើងដំណែង ឬការគ្រប់គ្រងទៅលើ **សមាជិកគ្រួសារណាម្នាក់** នៅក្នុងក្រុមហ៊ុនរបស់យើង។
- **បម្រើនៅក្នុងក្រុមប្រឹក្សាភិបាល ឬក្នុងក្រុមប្រឹក្សាយោបល់ផ្សេងទៀត** របស់អង្គភាព ដែលជាគូប្រជែង អតិថិជន ក្រុមហ៊ុនផ្គត់ផ្គង់ឲ្យក្រុមហ៊ុនរបស់យើង។

**សំណួរ** ប្អូនស្រីថ្លៃរបស់ខ្ញុំមានក្រុមហ៊ុនមួយ ដែលចង់ក្លាយជាក្រុមហ៊ុនផ្គត់ផ្គង់ឲ្យក្រុមហ៊ុនរបស់យើង។ គេបានផ្តល់សេវាកម្មបានល្អបំផុតក្នុងតម្លៃល្អបំផុត ហើយខ្ញុំចង់ទាក់ទងក្រុមហ៊ុនរបស់គាត់។ តើនេះចាត់ទុកជាទំនាស់ផលប្រយោជន៍ដែរឬទេ?

**ចម្លើយ** វាអាចចាត់ទុកជាករណីទំនាស់ផលប្រយោជន៍បាន បើទោះបីជាអ្នកយល់ថាក្រុមហ៊ុនប្អូនស្រីថ្លៃរបស់អ្នក នឹងផ្តល់នូវតម្លៃដល់ក្រុមហ៊ុនយើងប្រសើរជាងគូប្រជែងរបស់វាក៏ដោយ។ អ្នកគួរតែផ្តល់ព័ត៌មានពីស្ថានភាពនេះទៅដល់ប្រធានរបស់អ្នក ឬផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក។ អ្នកមិនគួរពាក់ព័ន្ធទៅក្នុងការសម្រេចចិត្ត ឬមានឥទ្ធិពលទៅលើការសម្រេចចិត្ត ថាតើត្រូវធ្វើអាជីវកម្មជាមួយក្រុមហ៊ុនប្អូនស្រីអ្នកឬក៏អត់នោះទេ។ ហើយប្រសិនបើក្រុមហ៊ុនប្អូនស្រីរបស់អ្នកក្លាយជាអ្នកផ្គត់ផ្គង់ក៏ដោយ អ្នកមិនគួរមានការសម្រេចចិត្ត ឬកាន់តំណែងគ្រប់គ្រងទាក់ទងទៅនឹងក្រុមហ៊ុនផ្គត់ផ្គង់ឡើយ ហើយគួរតែដកខ្លួនចេញពីឥទ្ធិពលលើទំនាក់ទំនងរវាងក្រុមហ៊ុនរបស់យើងនិងក្រុមហ៊ុនផ្គត់ផ្គង់។

## ការការពារ និងការប្រើប្រាស់ដ៏ត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងការការពារការបោកបន្លំ

យើងម្នាក់ៗមានកាតព្វកិច្ចការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនបង្ការ និងរាយការណ៍ពីការបោកបន្លំ និងការលួច។ ការបោកបន្លំការលួច ការធ្វេសប្រហែស និងការខ្ជះខ្ជាយ ផ្តល់ផលប៉ះពាល់ដោយផ្ទាល់ដល់ចំណូលរបស់ក្រុមហ៊ុនយើង។ លើកលែងតែត្រូវបានអនុញ្ញាត ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន រួមមាន ពេលវេលារបស់ក្រុមហ៊ុន បរិក្ខារ សម្ភារៈ ធនធាន និងព័ត៌មានសម្ងាត់ ត្រូវតែប្រើប្រាស់សម្រាប់តែការងារអាជីវកម្មរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។
នៅពេលអ្នកឈប់ពីក្រុមហ៊ុន ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ត្រូវតែផ្តល់មកដល់ក្រុមហ៊ុនវិញ។

**សំណួរ** ខ្ញុំអាចផ្តល់ព័ត៌មានអាជីវកម្មម្ហូបអាហាររបស់ភរិយាខ្ញុំដល់ក្រុមហ៊ុនផ្គត់ផ្គង់បានទេ?

**ចម្លើយ** មិនបានទេ។ ការផ្តល់ឲ្យក្រុមហ៊ុនផ្គត់ផ្គង់របស់យើងនូវព័ត៌មានស្តីពីក្រុមហ៊ុនផ្គត់ផ្គង់អាហាររបស់ភរិយាអ្នកមិនត្រូវបានអនុញ្ញាតឡើយ ពីព្រោះវានឹងពាក់ព័ន្ធដល់ការប្រើប្រាស់ធនធានរបស់ក្រុមហ៊ុន (បញ្ជីឈ្មោះក្រុមហ៊ុនផ្គត់ផ្គង់របស់យើង) សម្រាប់គោលបំណងអាជីវកម្មផ្ទាល់ខ្លួន។ ក្រុមហ៊ុនផ្គត់ផ្គង់របស់យើងអាចនឹងមានអារម្មណ៍ថាមានកាតព្វកិច្ចត្រូវធ្វើអាជីវកម្មជាមួយក្រុមហ៊ុនភរិយារបស់អ្នក ហើយករណីនេះអាចជះឥទ្ធិពលដល់ទំនាក់ទំនងរបស់ក្រុមហ៊ុនយើងជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់របស់យើង។

## ព័ត៌មានសម្ងាត់ និងកម្មសិទ្ធិបញ្ញាផ្សេងៗ

យើងមានការទទួលខុសត្រូវសព្វបែបយ៉ាងចំពោះការការពារព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនយើង និងភាគីទីបី ដោយក្នុងនោះក៏មានអតិថិជនផងដែរ។ យើងមិនបញ្ចេញព័ត៌មានសម្ងាត់ទៅដល់ជនណាម្នាក់ឡើយ ទាំងអ្នកខាងក្នុង និងខាងក្រៅក្រុមហ៊ុន ប្រសិនបើគ្មានភាពត្រឹមត្រូវតាមច្បាប់ ឬគ្មានការអនុញ្ញាតត្រឹមត្រូវឲ្យធ្វើបែបនេះទេនោះ។ យើងអនុវត្តទៅតាមគោលការណ៍របស់ក្រុមហ៊ុន ដើម្បីរក្សាព័ត៌មានរបស់ក្រុមហ៊ុនទប់ស្កាត់នឹងការលួច ឬប្រើប្រាស់ព័ត៌មានមិនត្រឹមត្រូវ។ ព័ត៌មានសម្ងាត់រាប់បញ្ចូលព័ត៌មានដែលមិនផ្សព្វផ្សាយជាសាធារណៈទាំងអស់ ដែលអាចនឹងត្រូវយកទៅប្រើដោយគូប្រជែង ឬបង្កគ្រោះថ្នាក់ដល់ក្រុមហ៊ុនរបស់យើង ឬអតិថិជនរបស់យើង និងភាគីទីបីដទៃផ្សេងទៀតក្នុងករណីបញ្ចេញទៅនោះ។ ឧទាហរណ៍នៃព័ត៌មានសម្ងាត់រួមមាន

- ទិន្នន័យហិរញ្ញវត្ថុ
- ព័ត៌មានសម្ងាត់ និងរូបមន្តពិសេសផ្នែកអាជីវកម្ម
- ឱកាសលទ្ធកម្មនិងការបញ្ជាឲ្យជំរុះចោល
- ព័ត៌មានអតិថិជននិងក្រុមហ៊ុនផ្គត់ផ្គង់
- ព័ត៌មានរបស់និយោជិតយើង
- ផែនការទីផ្សារ

កាតព្វកិច្ចរបស់អ្នកគឺត្រូវរក្សាព័ត៌មានជាការសម្ងាត់រហូតដល់ការបំពេញការងាររបស់អ្នកជាមួយក្រុមហ៊ុនត្រូវបានបញ្ចប់ ហើយអ្នកក៏មិនគួរបញ្ចេញព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនដែលអ្នកធ្វើការពីមុនមកឲ្យដល់ក្រុមហ៊ុនរបស់យើងផងដែរ។ បន្ថែមលើនេះទៀត យើងមិនប្រើប្រាស់មធ្យោបាយមិនស្របច្បាប់ ឬមិនមានក្រមសីលធម៌ (ដូចជាសកម្មភាពលួច ចារកិច្ច ឬការថ្លែងបោកប្រាស់) ដើម្បីទទួលបានព័ត៌មានសម្ងាត់របស់អ្នកដទៃ។

យើងក៏គោរព និងការពារកម្មសិទ្ធិបញ្ញារបស់ក្រុមហ៊ុនយើង និងក្រុមហ៊ុនដទៃផ្សេងទៀត។ មិនរំលោភលើកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ ពាណិជ្ជសញ្ញា និងទម្រង់ដទៃផ្សេងទៀតនៃកម្មសិទ្ធិបញ្ញា និងចាត់វិធាន ការសមស្របដើម្បី ការពារកម្មសិទ្ធិបញ្ញា។
ប្រសិនបើអ្នកមានសំ ណួរអំពីកម្មសិទ្ធិបញ្ញា សូមពិគ្រោះជាមួយផ្នែកនិតិកម្មនិងផ្នែកកម្មសិទ្ធិបញ្ញា។

**សំណួរ** អតីតមិត្តរួមការងារបានសុំខ្ញុំនូវរបាយការណ៍សម្ងាត់មួយច្បាប់ ដែលគាត់បានរៀបចំ នៅពេលគាត់កំពុងធ្វើការឲ្យក្រុមហ៊ុនរបស់យើង។ តើខ្ញុំអាចផ្តល់វាបានទេ?

**ចម្លើយ** មិនបានទេ។ តាមពិតទៅអតីតមិត្តរួមការងាររបស់អ្នកពីមុនមកបានចូលរួមក្នុងការរៀបចំរបាយការណ៍នៅពេលដែលគាត់កំពុងធ្វើការឲ្យក្រុមហ៊ុនរបស់យើង មិនមែនមានន័យថាគាត់ត្រូវបានអនុញ្ញាតឲ្យទទួលបានរបាយការណ៍នោះនៅពេលនេះទេ។ អ្នកគួរតែពិភាក្សាជាមួយនឹងប្រធានរបស់អ្នកអំពីរបៀបឆ្លើយតបចំពោះសំណើសុំនេះ។

## ប្រព័ន្ធអ៊ីនធើណិត និងការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន

ពួកយើងភាគច្រើនអាចប្រើប្រព័ន្ធអ៊ីនធើណិតបានតាមរយៈកុំព្យូទ័រនៅកន្លែងការងារ ឬផ្ទាល់ខ្លួន និងទូរសព្ទ។ យូរៗម្តង ការប្រើប្រាស់ផ្ទាល់ខ្លួននូវឧបករណ៍បច្ចេកវិទ្យានៅកន្លែងការងារ អាចនឹងត្រូវអនុញ្ញាត សូមធ្វើការប្រុងប្រយ័ត្នដើម្បីការពារកិត្តិសព្ទរបស់ក្រុមហ៊ុន និងព័ត៌មានអាជីវកម្មរបស់ក្រុមហ៊ុន។ សូមកុំដាក់ផ្សាយការផ្តល់មតិយោបល់នៅលើអ៊ីនធើណិត រួមទាំងប្រព័ន្ធទំនាក់ទំនងសង្គម ដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិសព្ទរបស់ក្រុមហ៊ុន ហើយមិនត្រូវបញ្ចេញមតិយោបល់ក្នុងនាមក្រុមហ៊ុន ប្រសិនបើអ្នកមិនត្រូវបានអនុញ្ញាតជាពិសេសឲ្យធ្វើដូច្នេះទេនោះ។

អ្នកគប្បីអនុវត្តទៅតាមគោលនយោបាយទាំងអស់របស់ក្រុមហ៊ុន នៅពេលប្រើប្រាស់ធនធានបច្ចេកវិទ្យារបស់ក្រុមហ៊ុននោះ។
វាសំខាន់ខ្លាំងណាស់ ដែលអ្នកត្រូវចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីផ្តល់សុវត្ថិភាពផ្នែក បច្ចេកវិទ្យារបស់ក្រុមហ៊ុន។ ប្រសិនបើអ្នកមានហេតុផលណាមួយជឿជាក់ថា លេខសម្ងាត់ ឬសន្តិសុខកុំព្យូទ័រ ទូរសព្ទ ឬធនធានបច្ចេកវិទ្យាដទៃផ្សេងទៀតរបស់ក្រុមហ៊ុន ស្ថិតក្នុងលក្ខណៈមួយមិនសមស្របនោះ អ្នកត្រូវតែប្តូរលេខសម្ងាត់របស់អ្នកភ្លាម ហើយរាយការណ៍ពីឧបត្តិហេតុ ប្រសិនបើស្ថិតក្នុង ប្រទេសជប៉ុន ទៅកាន់ប្រធានអចិន្ត្រៃយ៍ផ្នែកសន្តិសុខ ឬផ្នែកប្រចាំការជំនួយឧបត្តិហេតុសន្តិសុខតាមប្រព័ន្ធអ៊ីនធើណិត ឬក្នុងករណី ស្ថិតនៅក្រៅប្រទេសជប៉ុន ត្រូវរាយការណ៍ទៅកាន់ផ្នែកទទួលបន្ទុកបច្ចេកវិទ្យាព័ត៌មានរបស់អ្នក។

គ្រប់ឯកសារផ្ទាល់ខ្លួនទាំងអស់ ដែលត្រូវបានរក្សាទុកនៅក្នុងកុំព្យូទ័រក្រុមហ៊ុន គឺជាទ្រព្យសម្បត្តិក្រុមហ៊ុន។ យោងទៅតាមកម្រិតអនុញ្ញាតដោយច្បាប់ជាធរមាន ក្រុមហ៊ុនអាចនឹងពិនិត្យវាយតម្លៃឯកសារទាំងឡាយណាដែលត្រូវបានរក្សាទុក ឬបញ្ជូនតាមកុំព្យូទ័រ និងធនធានទំនាក់ទំនង ដោយក្នុងនោះរាប់បញ្ចូលទាំងសារអ៊ីម៉ែលផងដែរ។

**សំណួរ** ប្រធានរបស់ខ្ញុំសុំលេខសម្ងាត់កុំព្យូទ័ររបស់ខ្ញុំ ដោយសារតែខ្ញុំត្រូវឈប់សម្រាក។ តើធ្វើដូចនេះបានទេ?

**ចម្លើយ** មិនបានទេ។ គ្មានហេតុផលការងារណាមួយ ដែលនឹងតម្រូវឲ្យអ្នកត្រូវផ្តល់លេខសម្ងាត់ទៅដល់ប្រធានរបស់អ្នកនោះទេ។

## ការទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយនិងផ្នែកផ្សេងៗ

ក្រុមហ៊ុនរបស់យើងច្រើនទទួលបានសំណើសុំព័ត៌មានពីខាងប្រព័ន្ធផ្សព្វផ្សាយ អ្នកវិភាគហិរញ្ញវត្ថុ និងផ្នែកផ្សេងៗទៀត។ គោលបំណងរបស់យើងគឺទំនាក់ទំនងឲ្យបានត្រឹមត្រូវ ស្របគ្នា និងប្រតិបត្តិតាមច្បាប់សន្តិសុខទាក់ទងនឹងការងារបញ្ចេញព័ត៌មានអំពីក្រុមហ៊ុនសារណៈ។

ប្រសិនបើអ្នកមិនមែនជាមន្ត្រីនាំពាក្យក្រុមហ៊ុនទេនោះ អ្នកប្រហែលជាមិនអាចទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយបានទេ អ្នកវិភាគហិរញ្ញវត្ថុ ម្ចាស់ភាគហ៊ុន តាមប្រព័ន្ធទំនាក់ទំនងសង្គម ឬតាមរូបភាពអ្វីផ្សេងក្នុងនាមជាអ្នកតំណាងក្រុមហ៊ុនបានទេ លើកលែងតែអ្នកត្រូវបានអនុញ្ញាតជាពិសេសឲ្យធ្វើបែបនេះ ដោយផ្នែកទំនាក់ទំនងសាធារណៈនោះ។ សូមកុំព្យាយាមឆ្លើយសំណួរប្រព័ន្ធផ្សព្វផ្សាយដោយខ្លួនឯង បើទោះជាអ្នកគិតថាអ្នកដឹងចម្លើយក៏ដោយ។ សំណើសុំទាំងឡាយសម្រាប់ព័ត៌មានផ្នែកហិរញ្ញវត្ថុ ឬព័ត៌មានផ្សេងៗអំពីក្រុមហ៊ុន ធ្វើឡើងដោយប្រព័ន្ធផ្សព្វផ្សាយ សហគមន៍ហិរញ្ញវត្ថុ ម្ចាស់ភាគហ៊ុន ឬសាធារណជន គប្បីបញ្ជូនសំណើទាំងនោះទៅកាន់ផ្នែកទំនាក់ទំនងសាធារណៈ។ សំណើសុំទាំងឡាយសម្រាប់ព័ត៌មាន ធ្វើឡើងដោយនិយតករ រដ្ឋាភិបាល គប្បីបញ្ជូនទៅកាន់ផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋាន និងផ្នែកនីតិកម្ម។

**សំណួរ** ខ្ញុំកំពុងអានអត្ថបទអនឡាញមួយ ដែលមានព័ត៌មានមិនពិតអំពីអាជីវកម្មរបស់យើង។ ខ្ញុំចង់ធ្វើការឆ្លើយតប។ តើខ្ញុំអាចធ្វើបានទេ?

**ចម្លើយ** អ្នកមិនគួរធ្វើការឆ្លើយតបចំពោះអត្ថបទផ្សាយនោះទេ ប្រសិនបើអ្នកមិនត្រូវបានអនុញ្ញាតឲ្យធ្វើបែបនេះ ដោយផ្នែកទំនាក់ទំនងសាធារណៈទេនោះ ។ អ្នកគប្បីបញ្ជូនអត្ថបទចេញផ្សាយនោះទៅកាន់ផ្នែកទំនាក់ទំនងសាធារណៈជំនួសវិញ ឬក៏ទៅកាន់ផ្នែកនិតិកម្ម ដែលអាចឆ្លើយតបបានក្នុងនាមក្រុមហ៊ុន។



ការប្ដេជ្ញាចិត្តរបស់យើងចំពោះបុគ្គលិករបស់យើង

# និងបរិស្ថានរបស់យើង

## ធ្វើការគោរពគ្នាទៅវិញទៅមក

របៀបទំនាក់ទំនងគ្នាទៅវិញទៅមកប៉ះពាល់ដល់របៀបធ្វើការងាររបស់យើង។ យើងទាំងអស់គ្នាចង់បាន ការងារដែលស័ក្តិសម និងទទួល បាននៅកន្លែងធ្វើការ ហើយយើងទំនាក់ទំនងដោយការគោរពគ្នា។ យើងម្នាក់ៗមានការទទួលខុសត្រូវចូលរួមចំណែកបង្កើតឡើងនូវបរិយាកាសបែបនេះ ហើយប្រធានមានការទទួលខុសត្រូវជាពិសេស ដើម្បីជម្រុញឲ្យកន្លែងការងារគាំទ្រដល់ភាពស្មោះត្រង់ សុចរិតភាព ការគោរព និងការជឿទុកចិត្ត។

## ប្រឆាំងចំពោះការរើសអើង និងការរុកគួនរំខានឆាឆៅ

នៅក្រុមហ៊ុនរបស់យើង ផ្ដល់តម្លៃ គាំទ្រ និងគោរពចំពោះពិពិធភាព និងការបញ្ចូលគ្នា ជាគន្លឹះដើម្បីជោគជ័យរបស់យើងក្នុងនាមជាក្រុមហ៊ុនលំដាប់ពិភពលោក។ ហេតុនេះហើយ យើងមិនត្រូវរើសអើង គ្នាដោយ ផ្អែកលើជាតិសាសន៍ ជនជាតិ សញ្ជាតិ សាសនា អាយុ អត្តសញ្ញាណភេទ ចំណង់ផ្លូវភេទ ពិការភាព ឬលក្ខណៈដទៃផ្សេង ទៀតណាមួយឡើយ ដែលត្រូវបានការពារដោយច្បាប់ជាធរមានោះ។ រឿងកំប្លែងដែលមានលក្ខណៈប៉ះពាល់ជាក់លាក់ ការអត្ថាធិប្បាយ រូបភាព កាយវិការ ឬការប៉ះពាល់ណា ដែលទាក់ទងទៅនឹងលក្ខណៈហាមឃាត់ អាចនឹងចាត់ចូលជាការរុកគួនរំខានឆាឆៅ ដែលក្រុមហ៊ុនរបស់យើង មិនអត់ឱនឡើយ។

**សំណួរ** និយោជិត ខ្លះនៅក្នុងក្រុមរបស់ខ្ញុំនិយាយ កំប្លែងពីរូបរាងរបស់ខ្ញុំ។ ខ្ញុំដឹងថាពួកគេមិនមានចេតនាបង្កផលអាក្រក់អ្វីទេ ប៉ុន្តែការនិយាយកំប្លែងបែបនេះពិតជារំខានដល់ខ្ញុំ ហើយខ្ញុំបា នសុំឲ្យពួកគេបញ្ឈប់។ ពួកគេឆ្លើយតបថា ខ្ញុំគប្បីបង្កើននូវអារម្មណ៍បែបកំប្លែងរបស់ខ្ញុំឡើង។ តើខ្ញុំត្រូវធ្វើយ៉ាង ដូចម្ដេច?

**ចម្លើយ** អ្នកគួរតែ ជូនដំណឹងទៅផ្នែកគ្រប់គ្រងធនធានមនុស្ស ផ្នែកនីតិកម្ម ឬផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក។ “ការនិយាយកំប្លែង” ដែលអ្នកបានរៀបរាប់ មិនមែនជារឿងគួរឲ្យអស់សំណើចនោះទេ ចំពោះក្រុមហ៊ុនរបស់យើង។ ផ្ទុយទៅវិញវាអាចជាការរំលោភបំពាននៃការប្ដេជ្ញាចិត្តរបស់យើងចំពោះភាពយុត្តិធម៌ ការគោរព និងសេចក្ដីថ្លៃថ្នូរ។

**សំណួរ** អ្នកចង់ដាក់ពាក្យស្នើសុំ ការងារនៅផ្នែកផ្សេងទៀតនៃក្រុមហ៊ុនរបស់យើង ប៉ុន្តែអ្នកត្រូវបានគេប្រាប់ថា ប្រធានគ្រប់គ្រងតំណែងនេះ អាចស្នើបានតែ និយោជិតភេទប្រុសមានវ័យក្មេងប៉ុណ្ណោះ។ តើនេះ ត្រូវបានអនុញ្ញាតដែរឬទេ?

**ចម្លើយ** មិនអនុញ្ញាតទេ។ ក្រុមហ៊ុនមិនអនុញ្ញាតឲ្យមានឥរិយាបទរើសអើងអំពីអាយុ ភេទ ឬផ្នែកដទៃផ្សេងទៀតណាមួយឡើយ ដែលត្រូវបានការពារដោយច្បាប់ ដែលមានឥទ្ធិពលដល់សេចក្ដីសម្រេចចិត្តជួលបុគ្គលិកនោះ។ អ្នកគួរតែរាយការណ៍ពីបញ្ហាទៅដល់ ផ្នែកណាមួយដែលបានកំណត់នៅក្នុងក្រុម។

## សិទ្ធិឯកជនភាព និងទិន្និន័យបុគ្គល

យើងគោរពសិទ្ធិឯកជនភាព និងភាពថ្លៃថ្នូររបស់បុគ្គលគ្រប់រូប។ ក្រុមហ៊ុនរបស់យើងប្រមូល និងរក្សាទុកព័ត៌មានផ្ទាល់ខ្លួន ដែលទាក់ទងទៅនឹងការងារ រួមទាំងព័ត៌មានផ្នែកវិជ្ជសាស្ត្រ និងអត្ថប្រយោជន៍។ ប្រទេសជាច្រើនបញ្ញត្តិចំពោះ របៀបប្រមូល រក្សាទុក និងប្រើប្រាស់ “ទិន្នន័យបុគ្គល” ដែលក្នុងនោះរាប់បញ្ចូលទាំងឈ្មោះបុគ្គល អាសយដ្ឋាន និងព័ត៌មានផ្សេងៗទៀត។ ការយកចិត្តទុកដាក់ត្រូវអនុវត្តចំពោះការកំណត់ការចូលទៅប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនចំពោះបុគ្គលិកក្រុមហ៊ុនមានតម្រូវការត្រូវដឹងព័ត៌មានបែបនេះ សម្រាប់គោលបំណងការងារស្របច្បាប់។ និយោជិតទាំងឡាយណា ដែលទទួលខុសត្រូវចំពោះព័ត៌មានផ្ទាល់ខ្លួន និងអ្នកទាំងនោះដែលត្រូវបានផ្ដល់សិទ្ធិឲ្យប្រើប្រាស់ព័ត៌មានបែបនេះ មិនត្រូវបញ្ចេញព័ត៌មានឯកជនដោយរំលោភច្បាប់ជាធរមាន ឬគោលនយោបាយក្រុមហ៊ុនឡើយ។

អ្នកគប្បីដឹងច្បាស់ហើយអនុវត្តទៅតាមគោលនយោបាយទាំងនោះរបស់ក្រុមហ៊ុន និងច្បាប់ បទបញ្ញត្តិនានាជាធរមាន ពាក់ព័ន្ធ ទៅនឹងការងាររបស់អ្នក។

**សំណួរ** អ្នកដឹងថាមិត្តរួមការងាររបស់អ្នកកំពុងព្យាយាមប្រើអាសយដ្ឋាន និងលេខទូរសព្ទរបស់និយោជិតដទៃផ្សេងទៀត ដើម្បីផ្តល់ដំណឹងពីព្រឹត្តិសហគមន៍។ តើអ្នកគួរធ្វើអ្វីម៉្យាងទេ?

**ចម្លើយ** អ្នកគួរតែពន្យល់ដល់មិត្តរួមការងាររបស់អ្នកថា គាត់មិនអាចចូលយក ឬប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងទាំងនេះបានទេ។ ប្រសិនបើអ្នកជឿជាក់ថា គាត់អាចនៅតែបន្តព្យាយាមធ្វើបែបនេះនោះ អ្នកគួរតែរាយការណ៍បញ្ហាទៅប្រធានរបស់អ្នក ផ្នែកគ្រប់គ្រងធនធានមនុស្ស ឬប្រើប្រាស់និតិវិធីផ្សេងទៀតដូចមានកំណត់នៅក្នុងក្រមនេះ។

## សុវត្ថិភាពកន្លែងធ្វើការ

ក្រុមហ៊ុនប្តេជ្ញាចិត្តចំពោះការថែទាំ និយោជិតរបស់យើងឲ្យមានសុខភាពល្អ និងផ្តល់ទំនុកចិត្តដល់និយោជិតទាំងអស់ឲ្យទទួលបានកន្លែងធ្វើការមានសុវត្ថិភាព ហើយយើងទាំងអស់គ្នាមានទំនួលខុសត្រូវរួមចំណែកចំពោះរឿងនេះ។ អ្នកគួរតែយល់ឲ្យច្បាស់ និងអនុវត្តទៅតាមគោលការណ៍ណែនាំពីសុវត្ថិភាពទាំងអស់ និងលក្ខខណ្ឌការងារគ្មានសុវត្ថិភាព ឬគ្រោះថ្នាក់កន្លែងការងារ។ សកម្មភាព ឬការគំរាមកំ ហែងទាំងឡាយណា ដែលមានលក្ខណៈហឹង្សាជាពាក្យសម្តី ឬលើរូបរាង កាយចំពោះបុគ្គលណាម្នាក់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិក្រុមហ៊ុនខុសគោលដៅនោះ គប្បីត្រូវរាយការណ៍ភ្លាមទៅកាន់ផ្នែកសន្តិសុខ ប្រធានរបស់អ្នកឬធនធានក្រុមហ៊ុនសមស្របដទៃផ្សេងទៀត។

យើងមិនត្រូវរាយការណ៍ចំពោះការងារ ឬការងារមួយណាដែលស្ថិតក្រោមឥទ្ធិពលត្រូវបានហាមឃាត់ ឬគ្រឿងញៀន ឬគ្រឿងស្រវឹង។ គ្មាននិយោជិតណាម្នាក់មានសិទ្ធអាចយកអាវុធចូលក្នុងកន្លែងការងារ (លើកលែងតែត្រូវបានកំណត់ស្ថិតក្រោមច្បាប់ជាធរមាន)។

**សំណួរ** ប្រធានរបស់ខ្ញុំសុំឲ្យខ្ញុំឲ្យរំលងលក្ខខណ្ឌត្រូវត្រួតពិនិត្យផ្នែកសុវត្ថិភាពមួយចំនួនដើម្បីឲ្យទាន់កាលបរិច្ឆេទកំណត់។ តើខ្ញុំគួរធ្វើដូចម្តេច?

**ចម្លើយ** មិនត្រូវរំលងនិតិវិធីទំាងនេះទេ។ មិនថានរណាជាអ្នកប្រាប់អ្នកឲ្យធ្វើអ្វីមួយក៏ដោយ ក្នុងករណីអ្នកដឹងថាវាមិនត្រឹមត្រូវកុំធ្វើវា។ ប្រសិនបើអ្នកពិបាកពិភាក្សាបញ្ហានេះជាមួយប្រធានអ្នក សូមទាក់ទងប្រធានរបស់អ្នក ផ្នែកនីតិកម្ម ឬប្រភពណាមួយនៃផ្នែកដទៃផ្សេងទៀតដូចត្រូវបានកំណត់នៅក្នុងក្រមនេះ។

## គុណភាព

ក្រុមហ៊ុនរបស់យើងប្តេជ្ញាចិត្តផ្តល់ផលិតផលនិងសេវាកម្មប្រកបដោយគុណភាពខ្ពស់បំផុតជានិច្ច។ ការប្តេជាចិត្តចំពោះគុណភាពនេះ ពង្រីកទៅដល់គ្រប់ផ្នែកទាំងអស់នៃអង្គភាពរបស់យើង — គ្រប់អាជីវកម្ម និងគ្រប់ទីតាំងទាំងអស់។

**សំណួរ** យើងប្រើក្រុមហ៊ុនម៉ៅការឲ្យបោះចោលសារធាតុ ដែលបានបញ្ញត្តិដោយច្បាប់មួយចំនួន។ ផ្អែកតាមមតិមួយចំនួន ដែលខ្ញុំបានដឹងពីនិយោជិតរបស់គេ ខ្ញុំគិតថាពួកគេអាចនឹងមិនបោះចោលនូវសារធាតុទាំងនេះត្រឹមត្រូវស្របតាមច្បាប់ទេ។ ដោយសារតែវាជាក្រុមហ៊ុនម៉ៅការដែលស្ថិតក្រៅរង្វង់នៃការប្រតិបត្តិតាម តើវាមានបញ្ហាដល់យើងទេ?

**ចម្លើយ** បាទ/ចាស វាមានបញ្ហា។ អ្វីដែលក្រុមហ៊ុនម៉ៅការកំពុងធ្វើអាចបង្កើតឲ្យមានការទទួលខុសត្រូវដល់ក្រុមហ៊ុនរបស់យើង ហើយបើទោះបីគ្មានការទទួលខុសត្រូវផ្លូវច្បាប់ក៏ដោយ វាក៏នឹង នៅតែជាបញ្ហាដែរ។ កុំមើលទៅលើផ្លូវផ្សេងក្នុងករណីអ្នកមានហេតុផលគិតថាដៃគូអាជីវកម្មណាម្នាក់របស់យើងមិនស្ថិតក្នុងការប្រតិបត្តិតាមទេនោះ។ ពិភាក្សាជាមួយប្រធា នរបស់អ្នក ផ្នែកទំនាក់ទំនងប្រតិបត្តិតាមក្នុងមូលដ្ឋានរបស់អ្នក ផ្នែកនីតិកម្ម ឬធនធានណាមួយនៃធនធានទាំងឡាយរបស់យើងដូចបានកំណត់ក្នុងក្រមនេះ។

## ការអនុវត្តតាមផ្នែកបរិស្ថាន

ក្រុមហ៊ុនរបស់យើងប្តេជ្ញាចិត្តចំពោះការការពារបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថាននៃសកម្មភាពទាំងឡាយរបស់យើង។ យើងអនុវត្តទៅតាមច្បាប់បរិស្ថានដែលមានជាធរមានទាំងអស់។ យើងម្នាក់ៗត្រូវតែមានចំណេះដឹងពីការទទួលខុសត្រូវផ្នែកបរិស្ថាន ដែលអនុវត្តចំពោះការងាររបស់យើង និងការប្រកបអាជីវកម្មស្របទៅទាមតាមការទទួលខុសត្រូវទាំងនោះ។

## សិទ្ធិមនុស្ស

ក្រុមហ៊ុនរបស់យើងប្តេជ្ញាគាំទ្រ និងបង្កើនការគោរពសិទ្ធិមនុស្សនៅក្នុងគ្រប់សហគមន៍ទាំងអស់ដែលយើងធ្វើប្រតិបត្តិការ។ យើងប្រឆាំងចំពោះពលកម្មកុមារនិងទាសករ ហើយយើងចាត់ទុកមនុស្សគ្រប់ៗ គ្នាដោយសេចក្តីថ្លៃថ្នូរនិងការគោរព។ យើងក៏លើកទឹកចិត្តដល់ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនផ្គត់ផ្គង់ការងាររបស់យើង ឲ្យគាំទ្រនិង បង្កើនការគោរពសិទ្ធិមនុស្សផងដែរ។ យើងពេញចិត្តធ្វើការជាមួយអ្នកទាំងនោះ ដែលមានគុណតម្លៃដូចយើង និងគាំទ្រគុណតម្លៃក្រុមហ៊ុនយ៉ាងសកម្ម។

### ខ្ញុំកំពុងតែប្រឈមជាមួយនឹងការពិបាកសម្រេចចិត្តផ្នែកក្រមសីលធម៌។

# តើខ្ញុំត្រូវទៅរកនរណាឲ្យជួយ?



អ្នកត្រូវបានលើកទឹកចិត្តឲ្យសួរសំណួរ និងស្វែងរកការណែនាំ។ យើងទាំងអស់គ្នាមានការទទួលខុសត្រូវនិយាយការពិត និងរាយការណ៍ពីការប្រព្រឹត្តិ ដែលយើងជឿថាខុសច្បាប់ គ្មានសុវត្ថិភាព ឬគ្មានក្រមសីលធម៌។ ការលើកឡើងពីការព្រួយបារម្ភការពារទាំងក្រុមហ៊ុ និងនិយោជិតរបស់យើង។ មានមធ្យោបាយមួយចំនួន ដែលអ្នកអាចស្វែងរកការណែនាំ ឬលើកឡើងពីការព្រួយបារម្ភបាន។ ក្រុមហ៊ុនហាមឃាត់ការសងសឹកចំពោះនរណាម្នាក់ ដែលលើកឡើងនូវសំណួរ ឬក្តីកង្វល់ទាំងឡាយក្នុងន័យស្អាតស្អំ។



សូមទាក់ទងមកកាន់

**ផ្នែកគ្រប់គ្រងធនធានមនុស្ស**



សូមស្វែងរកការណែនាំពី

**ផ្នែកប្រតិបត្តិតាមក្នុងមូលដ្ឋាន**



សូមទាក់ទងមកកាន់

**ផ្នែកនីតិកម្ម**



សូមពិគ្រោះជាមួយ

**ប្រធានរបស់អ្នក**

សូមបញ្ជូនរបាយការណ៍តាមប្រព័ន្ធអនឡាញ ទូរសព្ទមកកាន់លេខពេលមានអាសន្ន ឬផ្ញើរអ៊ីម៉ែល៖

**http://global-sei.com/company/compliance-hotlines.html**

កំណត់សម្គាល់

កំណត់សម្គាល់

**ក្រមប្រតិបត្តិរបស់ក្រុមហ៊ុន Sumitomo Electric Group (Code of Conduct)**

គណៈកម្មការប្រតិបត្តិតាម ក្រុមហ៊ុន Sumitomo Electric Industries, Ltd.
(ការិយាល័យ: ក្រុមប្រតិបត្តិតាម ការិយាល័យប្រតិបត្តិតាម & គ្រប់គ្រងហានិភ័យ)
មេសា 2018 ការបោះពុម្ពផ្សាយលើកទីមួយ ក្រមប្រតិបត្តិ (Code of Conduct)

Sumitomo Electric Industries, Ltd.

Sumitomo Electric Industries, Ltd.
4-5-33 Kitahama, Chuo-ku
Osaka 541-0041, Japan

http://global-sei.com